សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំពីពាក្យបណ្តឹង

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២

**ស្រាវជ្រាវដោយ៖** **សាស្ត្រាចារ្យណែនាំ៖**

និស្សិតឈ្មោះ៖ **កញ្ញា ជូ ចនច័ន្ទលក្ស្មី** **លោក ហ៊ីង គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី ២២ ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ជូ ចនច័ន្ទលក្សី** ជានិស្សិតសិក្សានៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម L4A4 ជំនាន់ទី២២ ឆ្នាំសិក្សា២០១៨-២០២២។

នាងខ្ញុំដែលជាកូន សូមថ្លែងអំណរគុណ និងគោរពដល់លោកអ្នកមានគុណ ជាពិសេស គឺ **លោកឪពុក** និង **អ្នកម្តាយ** យ៉ាងជ្រាលជ្រៅគ្មានអ្វីប្រៀបផ្ទឹម ដែលបានចិញ្ចឹមបីបាច់ ថែរក្សា តាំងពីតូចរហូតដល់ធំ និងបានចំណាយទាំងថវិការ សម្ភារៈ ព្រមទាំងកម្លាំងកាយ ចិត្ត ដើម្បី ផ្គត់ផ្គង់ការសិក្សារបស់កូន តាំងពីបឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយមិនខ្លាចការ នឿយហត់ និងភាពលំបាក។ គោលបំណងតែមួយគត់របស់ពួកគាត់ គឺចង់ឃើញកូនៗមានអនាគត ល្អ។ គុណូបការៈរបស់ **លោកទាំងពីរ** ទោះជាយកមាសពេជ្យកែវកង ពិទូស្សរកាន មកប្រៀបផ្ទឹមក៏ មិនអាចស្មើបាន ហើយក៏មិនអាចរៀបរាប់ត្រឹមអត្ថបទមួយទំព័រនេះបានដែរ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតឲ្យនាងខ្ញុំ ចូលមកសិក្សា និង ក្រេបជញ្ជក់ចំណេះដឹងពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យដែលពោពេញដោយចំណេះដឹង និង បទពិសោធន៍យូរឆ្នាំនិងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកសាស្ត្រាចារ្យ ហ៊ីង គីមឡេង** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការជួយដឹកនាំ ពន្យល់ បង្ហាត់បង្ហាញ និងលើកទឹកចិត្តដល់ នាងខ្ញុំ ក្នុងដំណើរការនៃការសរសេរសារណានេះឲ្យចេញជារូបរាងឡើងដើម្បីបញ្ចប់ ថ្នាក់បរិញ្ញាបត្រនេះ។

ជាចុងបញ្ចប់នាងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធដែលមាននៅក្នុងលោក និង ទេវត្តាឆ្នាំថ្មី មេត្តាជួយតាមថែរក្សា **លោកប៉ា អ្នកម៉ាក់** និង សាស្ត្រាចារ្យទាំងអស់ ដែលបង្រៀន នៅ **សាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឲ្យជួបប្រទះតែនឹងពុទ្ធពរ ទាំងឡាយ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងអស់រយៈពេល ៤ឆ្នាំ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នាងខ្ញុំបានជ្រើសរើស យកប្រធានបទស្តីអំពី "**អំពីពាក្យបណ្តឹង**" ដើម្បីយកមកធ្វើការ ស្រាវជ្រាវ និងចងក្រងជាឯកសារដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រោម ការដឹកនាំរបស់**លោក គ្រូសាស្ត្រាចារ្យ ហ៊ីង គឹមឡេង** ។

ការជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ ដោយសារតែយល់ឃើញថា ប្រធានបទនេះថ្មី ដែលមិនទាន់មានអតីតនិស្សិតរូបណាបានស្រាវជ្រាវ និងតម្កល់ទុកជាឯកសារ នៅក្នុងបណ្ណាល័យសិក្សានៅឡើយទេ។ ម្យ៉ាងទៀត ប្រធានបទមួយនេះ នឹងអាចជួយដល់មិត្តអ្នកអាន ឬ អ្នកស្រាវជ្រាវ ក៏ដូចជាប្រជាពលរដ្ឋមួយចំនួន ដែលជួបប្រទះនឹងបញ្ហាវិវាទក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយការពឹងពាក់ឲ្យ តុលាការជួយស្វែងរកនូវដំណោះស្រាយតាមរយៈពាក្យបណ្តឹងរបស់ខ្លួន។

នាងខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណា ទាក់ទងនឹង ការសរសេរពាក្យបណ្តឹង និងអង្គហេតុចម្បង ដោយមានការណែនាំពីលោកគ្រូ សាស្ត្រាចារ្យ ដែលលោក បានផ្តល់ជាយោបល់ពន្យល់ណែនាំ ដើម្បីអាចសរសេរសារណា មួយនេះបានទៅដោយរលូន ដោយល្អ និងត្រឹមត្រូវ ជាពិសេស នាងខ្ញុំបានបញ្ចប់ការសរសេរសារណាមួយនេះដោយជោគជ័យ។ ការសរសេរសារណាមួយនេះឡើង ពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះនាងខ្ញុំរង់ចាំទទួលនូវការរិះគន់ដើម្បីស្ថាបនាពី សំណាក់សាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈ ដើម្បីកែលម្អសារណា មួយនេះឲ្យកាន់តែមានភាពល្អប្រសើរដែលអាចទទួលយកបាន។

នាងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងក្លាយជាឯកសារស្រាវជ្រាវដ៏សំខាន់ដល់មិត្ត និស្សិតគ្រប់ជំនាន់ និងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈ ដើម្បីយកវាទៅអនុវត្តនៅក្នុងវិជ្ជាជីវៈ និងជីវភាពរស់នៅប្រចាំថ្ងៃ ដែលកំពុងជួបនឹងបញ្ហាវិវាទនានា ដែលឈានទៅដល់ការពឹង ពាក់តុលាការដើម្បីជួយស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម**.........................................................................................................

## ជំពូកទី១
## បណ្ដឹង

**ផ្នែកទី១.អត្ថន័យនៃពាក្យបណ្ដឹង**..........................................................................................២

១.ទម្រង់នៃពាក្យបណ្ដឹង..................................................................................................... ៣

១.២.ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង.................................................................... ៣

១.២.១..ឈ្មោះ និងអាសយដ្ឋានរបស់គូភាគី............................................................................ ៣

១.២.២.ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដែលច្បាប់បានកំណត់.................................................៤

១.២.៣.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ .........................................៥

១.២.៤.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ .......................................................................៦

**ផ្នែកទី២. ចំណុចដែលគួរគប្បីសរសេរក្នុងពាក្យបណ្ដឹង**.............................................................. ៨

២.អង្គហេតុដែលជាមូលហេតុនៃការទាមទារ......................................................................... ៨

២.១.អង្គហេតុសំខាន់ៗដែលទាក់ទងនឹងការទាមទារ(អង្គហេតុប្រយោល) .................................. ៩

២.២.ភស្តុតាង ..................................................................................................................១៥

## ជំពូកទី២
## ប្រភេទនៃពាក្យបណ្ដឹង

**ផ្នែកទី១.បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក**.............................................................១៨

៣.បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន......................................................................១៨

៣.១.បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត.........................................................................១៩

៣.២.សាលក្រមនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក...........................................................................១៩

**ផ្នែកទី២.បណ្ដឹងទាមទារឲ្យបញ្ជាក់**............................................................................២០

៤.អត្ថន័យនៃបណ្តឹងទាមទារឲ្យបញ្ជាក់ ........ ១៨
៤.១.កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបញ្ជាក់ ........ ២០
៤.២សាលក្រមនៃបណ្តឹងទាមទារឲ្យបញ្ជាក់ ........ ២២
**ផ្នែកទី៣.បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត** ........ ២៣
៥.អត្ថន័យនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ ២៣
៥.១.កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់នូវទំនាក់ទំនងគតិយុត្ត ........ ២៤
៥.២.សាលក្រមនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ ២៤
**ជំពូកទី៣**
**អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬអង្គហេតុចម្បង**
**ផ្នែកទី១.ទ្រឹស្តី និងការបែងចែកអង្គហេតុ** ........ ២៦
៦.តួនាទីនៃអង្គហេតុចម្បងក្នុងសកម្មភាពបណ្តឹងជាក់ស្តែង ........ ២៧
៦.១.អង្គហេតុដែលនាំឲ្យមានការកើតឡើងនូវសិទ្ធិ ........ ២៩
៦.២.អង្គហេតុដែលនាំឲ្យរលត់សិទ្ធិ ........ ២៩
៦.៣.អង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ ........ ២៩
៦.៤.អង្គហេតុរារាំងការកើតឡើងសិទ្ធិ ........ ២៩
**ផ្នែកទី២.លំហូរនៃការបញ្ជាក់អង្គហេតុ** ........ ៣០
៧.ការទាមទារ ........ ៣០
៧.១.កម្មវត្ថុនៃបណ្តឹង ........ ៣០
៧.២.មូលហេតុនៃការទាមទារ ........ ៣១
៧.៣.ការអះអាង ........ ៣២
៧.៤.មូលហេតុដែលអនុញ្ញាតឲ្យធ្វើការអះអាង ........ ៣២
៧.៥ដំណាក់កាលនៃការអះអាង ........ ៣៣
៧.៦.ការទទួលខុសត្រូវក្នុងការអះអាង ........ ៣៣
៧.៧.អង្គហេតុដែលត្រូវការវាយតម្លៃ ........ ៣៤

៧.៨.ការបញ្ជាក់(ភស្តុតាង និង អង្គហេតុ) ............ ៣៥
៧.៩.អត្ថន័យ និងភាពចាំបាច់ក្នុងការទទួលខុសត្រូវក្នុងការបញ្ជាក់............ ៣៥
៧.៩.១.វិធីបញ្ជាក់ភស្តុតាងនៃអង្គហេតុ............ ៣៦
៧.៩.២.ការទទួលខុសត្រូវក្នុងការបញ្ជាក់ និងអត្ថន័យ............ ៣៦
៧.៩.៣.ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ............ ៣៨
៧.៩.៤.ការសន្មតតាមផ្លូវច្បាប់ និងការពិតជាបណ្តោះអាសន្ន............ ៣៩
**សេចក្តីសន្និដ្ឋាន** ............ ៤១
**អនុសាសន៍** ............ ៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងសង្គមសព្វថ្ងៃសង្កេតឃើញថាមានកើតឡើងនូវជម្លោះ ឬវិវាទជាច្រើន រវាងបុគ្គលឯកជននិង បុគ្គលឯកជន នីតិបុគ្គលឯកជននិង បុគ្គលឯកជន ឬនីតិបុគ្គលឯក ជននិងបុគ្គលឯកជនក៏មានដែរ ។ រីឯការដោះស្រាយវិវាទវិញ នាពេលបច្ចុប្បន្នត្រូវបាន ដំណើរការឡើងតាមពីររបៀបគឺតាមប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ ។

ការដោះស្រាយតាមប្រព័ន្ធតុលាការចាំបាច់ត្រូវភាគីនៃវិវាទនាំយកនូវបណ្តឹងទៅ កាន់តុលាការ។ បណ្តឹងជាទម្រង់បទដ្ឋានគតិយុត្តិដែលធ្វើឡើងដើម្បីទាមទារឲ្យតុលាការចេញសេចក្តីសម្រេចដំណោះស្រាយលើវិវាទរបស់ខ្លួន ហើយបណ្តឹងអាចធ្វើឡើង បាន ក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជា វិវាទតាមផ្លូវច្បាប់ជាក់ស្តែង និងដែល វិវាទនោះអាចដោះស្រាយដោយសាលក្រម (មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ការធ្វើបណ្តឹងត្រូវបានធ្វើឡើងតាមពីររបៀបគឺ បណ្តឹងដែលធ្វើជាលាយលក្ខ័អក្សរ និង បណ្តឹងដែលធ្វើឡើងដោយផ្ទាល់មាត់(បណ្តឹងដែលមានចំនួនទឹកប្រាក់តិច)។

ម៉្យាងវិញទៀតទម្រង់នៃបណ្តឹងតម្រូវឲ្យគោរពតាមមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីការពារពីហានិភ័យក្នុងការបញ្ជូនឲ្យដីការតុលាការឲ្យទៅគូភាគី ឬការបញ្ជាក់ពីកម្មវត្ថុនៃការទាមទាររបស់ដើមចោទដែលមានភាពសមស្របតាមច្បាប់ទៅ និងសមត្ថកិច្ចរបស់តុលាការ ពោលគឺគុណភាពនៃបណ្តឹងនោះមានលទ្ធភាពអាចឲ្យតុលាការដោះស្រាយបានដែលរឺទេ ។

ហេតុដូច្នេះ តើបណ្តឹងជាអ្វី?ហើយអ្វីជាអង្គហេតុចម្បង? ហើយតើពាក្យបណ្តឹង មានទម្រង់បែបណា? តើចំណុចអ្វីខ្លះដែលត្រូវសរសេរក្នុងពាក្យបណ្តឹង? ដើម្បីងាយស្រួលធ្វើការបកស្រាយបញ្ហាគតិយុត្តិទាំងនេះ ក្រុមសិក្សាស្រាវជ្រាវនាងខ្ញុំ នឹងធ្វើការបង្ហាញជូនមិត្តអ្នកអាន និងអ្នកស្រាវជ្រាវគ្រប់ស្រទាប់វណ្ណៈនូវប្លង់សិក្សាពីរជំពូក៖ (១) បណ្តឹង (២) ប្រភេទនៃពាក្យបណ្តឹង និង(៣) អង្គហេតុចម្បង ឬអង្គហេតុដែលជាមូលហេតុនៃការទាមទារដែលនឹងធ្វើការលម្អិតជូនក្នុងខ្លឹមសារអត្ថបទខាងក្រោម៖

# ជំពូកទី១

# បណ្តឹង

## ផ្នែកទី១. អត្ថន័យនៃបណ្តឹង

### ១.ទម្រង់នៃពាក្យបណ្តឹង

បណ្តឹងសំដៅលើសកម្មភាពទាមទារមួយ ដែលធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយទៅកាន់តុលាការនៃការជំនុំជម្រះក្តី ដោយបានអះអាងពីអត្ថិភាព ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកទៅលើការអះអាងទាំងនេះ តាមរយៈការដាក់ពាក្យបណ្តឹង។ បណ្តឹងអាចកើតមានចាប់ពីពេលដែលមានការដាក់ពាក្យបណ្តឹងដូច្នេះ នីតិវិធីបណ្តឹងនឹងត្រូវចាប់ផ្តើម។បុគ្គលណាក៏ដោយដែលមានសមត្ថភាពតាមផ្លូវច្បាប់សុទ្ធតែអាចធ្វើពាក្យបណ្តឹង ដើម្បីឲ្យតុលាការធ្វើការសម្រេចសេចក្តីចំពោះការទាមទាររបស់ខ្លួន ហើយការធ្វើបណ្តឹងអាចធ្វើពាក្យបណ្តឹងអាចធ្វើឡើងដោយបុគ្គលឯកជនខ្លួនឯង ឬតាមរយៈអ្នកតំណាងដោយអាណាត្តិដែលខ្លួនបានជ្រើសរើស ដែលអ្នកតំណាងដែលអាចធ្វើសកម្មភាពបណ្តឹងក្នុងន័យនេះគឺត្រូវតែជាមេធាវី លើកលែងតែករណីពិសេសមួយចំនួនដូចមានចែងនៅក្នុងមាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី [១]។ ទោះបីជាបណ្តឹងត្រូវបានធ្វើឡើងដោយភាគីខ្លួនឯងក្តី ឬដោយមេធាវីក្តីក៏បណ្តឹងនោះចាំបាច់ត្រូវតែគោរពតាមវិធានដែលកំណត់អំពីចំណុចផ្សេងៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងដូចមានកំណត់ក្នុងមាត្រា ៧៥ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី [២] ។

ដូច្នេះបណ្តឹងដែលធ្វើឡើងដោយពុំបានគោរពតាមវិធាននានាដូចមានកំណត់ដូចមានកំណត់ក្នុងមាត្រាខាងលើនេះទេនោះតុលាការអាចលើកបណ្តឹងនោះចោលដោយសេចក្តីសម្រេច។កាលណាតុលាការទទួលបានពាក្យបណ្តឹង តុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹង ដោយធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ និងចេញសេចក្តីសម្រេចតាមរយៈសាលក្រម។សាលក្រមគឺជាលទ្ធផលចុងក្រោយរបស់បណ្តឹង ដែលតុលាការត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់ភាគីតាមរយៈការទាមទារនានានៅក្នុងបណ្តឹងមានន័យថា បើភាគីតាមទារអ្វីមួយ តុលាការត្រូវធ្វើការឆ្លើយតបទៅនឹងការទាមទារនោះ បន្ទាប់ពីខ្លួនយល់ឃើញ ឬសំអាងហេតុដែលកើតចេញពីអំណះអំណាងរបស់ភាគី ដោយមានការផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាង។ដូច្នេះជាគោលការណ៍ តុលាការធ្វើជំនុំជម្រះ និងចេញសាលក្រមត្រឹមតែទំហំដែលបានទាមទារនៅក្នុងបណ្តឹងតែប៉ុណ្ណោះ។

[១] មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២] មាត្រា ៧៥ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**ចំណុចដែលត្រូវសរសេរ [៣] ដើម្បីឲ្យពាក្យបណ្តឹងមានសុពលភាព គេហៅថា ចំណុច ចំបាច់ដែលត្រូវសរសេរបញ្ជាក់នៃពាក្យបណ្តឹង ។**

តាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាការប្តឹង ត្រូវធ្វើដោយដាក់ ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ទៅតុលាការ ។

**នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖**

**ក. ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។**

**ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និង អង្គ ហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។**

នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច (ខ) ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឲ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការ ទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុ សំខាន់ ។ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទង នឹងអង្គហេតុដែលជាមូលហេតុ នៃការទាមទារ និង ភស្តុតាង ។ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន ត្រូវចាត់ជា ឯការសារត្រៀមផងដែរ ។

## ១.២. ភាគី និង អ្នកតំណាងតាមផ្លូវបណ្តឹង

**ភាគី (ដើមចោទ និង ចុងចម្លើយ)**[៤] (មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ក) ភាគី គឺជាឈ្មោះទូទៅនៃដើមចោទដែលបាន ធ្វើបណ្តឹងទាមទារឲ្យចេញសាលក្រម និងចុងចម្លើយដែលភាគីម្ខាងទៀតនៃបណ្តឹង នោះ។ ពេលដែលបានដាក់ពាក្យបណ្តឹងហើយ តុលាការត្រូវមានករណីកិច្ចធ្វើការវិនិច្ឆ័យ ស្តីពីវិវាទរវាងដើមចោទ និងចុងចម្លើយនោះ ហើយជាគោលការណ៍ អានុភាពនៃសាល ក្រមដែលចេញដោយតុលាការ នឹងមានឥទ្ធិពលទៅលើភាគី ហើយត្រូវចងភាគី [៥]នោះ (មាត្រា ១៩៨ កថាខណ្ឌទី១) ។ ដូច្នេះ ក្នុងពាក្យបណ្តឹង តើអ្នកណាជាដើមចោទ តើអ្នកណា ជាចុងចម្លើយនោះ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់ដើម្បីកុំឲ្យមានការច្រឡំនឹងអ្នកផ្សេង ប្រសិនបើរូបវន្ត

---

[៣] ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៤] មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ក

[៥] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩៨ ចំណុច ក

បុគ្គល ត្រូវសរសេរអំពីអាសយដ្ឋាន និងឈ្មោះអ្នកនោះប្រសិនបើនីតិ បុគ្គល[៦]វិញត្រូវសរសេរនាមករណ៍ ឬឈ្មោះ និងទីតាំងនៃទីស្នាក់ការរបស់នីតិបុគ្គលនោះ (បើជាក្រុមហ៊ុន គឺទីស្នាក់ការនាយ)ហើយបង្ហាញឲ្យបាន ច្បាស់លាស់អំពីដើមចោទ និង ចុងចម្លើយ (ប្រសិនបើអាចធ្វើទៅបាន គួរតែបញ្ជាក់អំពីអាសយដ្ឋានដើមតាម ច្បាប់ អាយុ ភេទ ជាអាទិ៍ផងដែរ) ។

### ១.២.១. អ្នកតំណាងតាមផ្លូវបណ្តឹង

អ្នកតំណាងតាមផ្លូវបណ្តឹង គឺជាអ្នកធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬភាគីម្ខាងទៀត ដោយផ្អែកលើឆន្ទៈរបស់ខ្លួន ក្នុងនាមជាភាគី ហើយជំនួសភាគី ហើយអានុភាពនៃការធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាព បណ្តឹងនោះនឹងមានទៅលើភាគី ។ អានុភាពសកម្មភាពរបស់អ្នកតំណាង មានទៅលើ សាមីខ្លួន ដោយសារតែអ្នកតំណាងនោះមានសិទ្ធិតំណាង ។ ចំពោះអ្នកតំណាងតាមផ្លូវ បណ្តឹងមាន (**អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។**

- **អ្នកតំណាងដែលច្បាប់បានកំណត់** ៖ ក្នុងករណីមានការពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹងជាបឋមភាគីជាអនីតិជន ឬ ជាជននៅក្រោយអាណាព្យាបាលទូទៅ ហេតុនេះហើយ ជនដែលត្រូវបានផ្តល់នូវសិទ្ធិតំណាងដែលច្បាប់បានកំណង តាមផ្លូវច្បាប់សារធាតុ អ្នកតំណាងតាមផ្លូវច្បាប់សារធាតុ) ដូចជាអ្នកមានសិទ្ធិ អំណាចមេបានលើ អនីតិជននោះ ឬ អ្នកអាណាព្យាបាលទូទៅ ជាដើមដែល អាចក្លាជាអ្នកតំណាងដែលច្បាប់បានកំណត់[៧]តាមផ្លូវនីតិវិធីបណ្តឹង សម្រាប់ អនីតិជន ឬជននៅក្រោមអាណាព្យាបាលនោះផលដែរ។ ម៉្យាងទៀត ប្រសិនបើគ្មានមានអ្នកតំណាងដែលច្បាប់កំណត់តាមផ្លូវច្បាប់សារធាតុ ឬ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ពុំអាចអនុវត្តសិទ្ធិតំណាងរបស់ ខ្លួនបាន តុលាការអាចជ្រើសតាំងអ្នក តំណាងពិសេស[៨](មាត្រា ៣៦ នៃក្រម នីតិវិធីរដ្ឋប្បវេណី) សម្រាប់ជនដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះ បុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយផ្អែកលើពាក្យសុំរបស់ បុគ្គលនោះ ។

---

[៦] ក្រមនីតិវីរដ្ឋប្បវេណី មាត្រា ៣២
[៧] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[៨] មាត្រា ៣៦ នៃក្រម នីតិវិធីរដ្ឋប្បវេណី

- **អ្នកតំណាងដោយអណត្តិ** ៖ ជាគោលការណ៍ ជនដែលអាចក្លាយទៅជាអ្នក តំណាងដោយអាណត្តិ មានតែមេធាវីទេ (គោលការណ៍នៃការតំណាងដោយ មេធាវី[៩] មាត្រា ៥៣ កថាខណ្ឌទី១) នេះដើម្បីការពារផលប្រយោជន៍សាមីភាគីដែលជាអ្នកពឹងពាក់ ។
- **ករណីពិសេស** ៖ ស្ដីពីករណីដែលអាចជ្រើសតាំងជនក្រៅពីមេធាវីធ្វើអ្នក តំណាងដោយអាណត្តិ ក្រមនីតិវិធីរដ្ឋប្បវេណីបានទទួលស្គាល់ករណីដូចជា៖

(**១**). ករណីដែលទទួលស្គាល់ឲ្យតតិយជនក្រៅពីមេធាវី ធ្វើសកម្មភាពបណ្ដឹង ជំនួសភាគី[១០] ដោយយោងតាមច្បាប់ (មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ក) ។

(**២**). ករណីដែលរដ្ឋ ឬ ស្ថាប័នរដ្ឋ ជាអាទីជាភាគី ហើយមានការកំណត់ឲ្យ មន្ត្រីស្ថាប័នោះធ្វើជាអ្នកតំណាងស្ថាប័ន[១១] នោះ (មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ២) ។

(**៣**). ករណីដែលអនុញ្ញាតឲ្យតតិយជនពិសេសក្រៅពីមេធាវីធ្វើជាអ្នក តំណាងក្នុងរឿងក្ដីដែលទឹកប្រាក់នៃកម្មវត្ថុនៃបណ្ដឹងនោះ (តិចជាង ១,000,000 លានរៀល) ។

ផ្ទុយទៅវិញ ក្នុងពាក្យបណ្ដឹង ការសរសេរបញ្ជាក់អំពីអ្នកតំណាងដោយ អាណត្តិ មិនមែនជាចំណុចដែលចាំបាច់សរសេរបញ្ជាក់ក្នុងពាក្យបណ្ដឹងទេ ។ ដូច្នេះ ហើយទោះបីជាមានកង្វះអំពីការសរសេរបញ្ជាក់ស្ដីពីអ្នកតំណាងដោយអាណត្តិក្នុង ពាក្យបណ្ដឹងក៏ដោយ ក៏មិនមែនជាកម្មវត្ថុនៃការបង្គាប់ឲ្យកែតម្រូវពាក្យបណ្ដឹងទេ ។

### ១.២.២.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

ក្នុងពាក្យបណ្ដឹង ដើមចោទត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនទាមទារ។ការសរសេរបញ្ជាក់អំពីសាលក្រមដែលចង់ឲ្យតុលាការចេញនោះ គឺជាចំណុចមួយដែលចាំបាច់ត្រូវសរសេរបញ្ជាក់ក្នុងពាក្យបណ្ដឹង។ការសរសេរបញ្ជាក់អំពីសាលក្រមដែលទាមទារនេះ គឺដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីការអះអាងសិទ្ធិរបស់ដើមចោទ លើកម្មវត្ថុនៃការប្ដឹងទាមទារនោះ។នៅក្នុងពាក្យបណ្ដឹង គឺត្រូវសរសេរបញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ និង ត្រូវសរសេរបញ្ជាក់អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារបើយោងតាមចំណុចទាំងពីរនេះ គេអាចបញ្ជាក់នូវការទាមទារតាមផ្លូវបណ្ដឹង

[៩] មាត្រា ៥៣ កថាខណ្ឌទី១

[១០] មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ក

[១១] មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ២

បាន។ ការទាមទារតាមផ្លូវបណ្តឹង គឺជាការអះអាងស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់សារធាតុ[១២]ដែលបានកំណត់ តាមរយៈបណ្តឹងរបស់ដើមចោទចំពោះចុងចម្លើយ ហើយការអះអាងនោះ គឺជាកម្មវត្ថុ ឬ ជាមូលដ្ឋានក្នុងការពិចារណានៅពេលធ្វើការជំនុំជម្រះ និង វិនិច្ឆ័យដើម្បីសម្រេចសេចក្តីនៃបណ្តឹង។ ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺជាអត្ថន័យនៃសាលក្រមដែលដើមចោទចង់ឱ្យតុលាការសម្រេចសេចក្តី ដូចអ្វីដែលមានសរសេរនៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។ ម៉្យាងទៀត ការសរសេរពីខ្លឹមសារនៃសាលក្រម ដែល ដើមចោទទាមទារឱ្យតុលាការចេញ នៅក្នុងពាក្យបណ្តឹង គឺមានភាពខុសប្លែកពីគ្នាដោយផ្អែកទៅតាមប្រភេទនៃបណ្តឹង។

**ឧទាហរណ៍៖**

- **ករណីនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក** ( ទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ចុងចម្លើយត្រូវសងប្រាក់១០លានរៀលទៅដើមចោទ )
- **ករណីបណ្តឹងទាមទារឲ្យបញ្ជាក់អត្ថិភាពឬ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត** ( ទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ដើមចោទពិតជាមានកម្មសិទ្ធិលើដីធ្លីដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីអចលនវត្ថុដែលមានភ្ជាប់ជាមួយ )។
- **ករណីនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត** ( ទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ដើមចោទ និងចុងចម្លើយត្រូវលែងលះគ្នា )។

### ១.២.៣.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

ពាក្យថាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ក្នុងនេះមានន័យថា ជាអង្គហេតុចាំបាច់សម្រាប់បញ្ជាក់( បង្ហាញ )អំពីការអះអាងអំពីសិទ្ធិ ការទាមទារតាមផ្លូវបណ្តឹងដែលដើមចោទទាមទារឲ្យតុលាការធ្វើការជំនុំជម្រះ និងចេញសាលក្រមនៃបណ្តឹងនេះដើម្បីកុំឲ្យមានការភាន់ច្រឡំ និងការមិនអាចបែងចែកបានទៅនឹងការទាមទារផ្សេងទៀតរួមជាមួយនឹងការសរសេរអំពីសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹង ហើយមូលហេតុចាំបាច់ដែលត្រូវតែសរសេរអំពីអង្គហេតុចាំបាច់ គឺដើម្បីបញ្ជាក់នូវការទាមទារ នៅក្នុងពាក្យបណ្តឹង និងដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬ មានការបែងចែកមិនច្បាស់លាស់នូវការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង

[១២] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៤

ជាមូលដ្ឋាននៃការពិចារណាសម្រាប់ធ្វើការវិនិច្ឆ័យសម្រេចសេចក្តី ទាក់ទងទៅនឹងការទាមទារផ្សេងទៀត មានន័យថា សម្តៅទៅលើអង្គហេតុ ដែលអាចធ្វើការសម្គាល់កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអះអាងដោយដើមចោទ និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដទៃទៀត។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺមានលក្ខណៈខុសគ្នាទៅតាមប្រភេទនៃសិទ្ធិ និង ទំនាក់ទំនងគតិយុត្តនីមួយៗ។ ឧទាហរណ៍ទី១៖ ករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិប្រត្យក្ស ដែលជាសិទ្ធិផ្តាច់មុខ(លើកលែងតែសិទ្ធិប្រាតិភោគប្រត្យក្ស) សិទ្ធិនោះមិនអាចមានអត្ថិភាពជាន់គ្នាលើកម្មវត្ថុតែមួយបានទេ ដូចជាករណីដែល នៅលើអចលនវត្ថុ(ដី)មួយកន្លែងមិនអាចមានម្ចាស់កម្មសិទ្ធិពីរលើដីតែមួយបានឡើយ។ ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិ គឺគ្រាន់តែសរសេរអំពីប្រធាននៃសិទ្ធិ(ដើមចោទ) កម្មវត្ថុនៃសិទ្ធិ(ទីតាំងអចលនវត្ថុ"ដី"នៅកន្លែងណាមួយ) រួមទាំងប្រភេទ និង ខ្លឹមសារនៃសិទ្ធិ(សិទ្ធិលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ជាដើម។ល។) គឺគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ទី២៖ ករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិលើបំណុល គឺដើមចោទអាចមានសិទ្ធិច្រើនចំពោះចុងចម្លើយ ដោយមូលហេតុនៃការបង្កើតសិទ្ធិនោះផ្សេងគ្នា។ ហេតុនេះ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិដើមចោទត្រូវសរសេរនៅក្នុងពាក្យបណ្តឹងអំពីប្រធាននៃសិទ្ធិ , កម្មវត្ថុនៃសិទ្ធិ , ប្រភេទនៃសិទ្ធិ , ខ្លឹមសារនៃសិទ្ធិ និង មូលហេតុនៃការបង្កើតសិទ្ធិ។ ករណីសិទ្ធិទាមទារឱ្យបង់ប្រាក់ចំនួនកំណត់មួយ ដែលអាចមានអត្ថិភាពដោយសារជាសិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ឬ ជាសិទ្ធិទាមទារប្រាក់ថ្លៃលក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ឬ ជាសិទ្ធិទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ជាដើម ឧទាហរណ៍៖ ការទាមទារឲ្យភាគីចុងចម្លើយអនុវត្តនូវកាតព្វកិច្ច ដោយត្រូវយកប្រាក់ចំនួន ៥០០ ដុល្លាអាមេរិក មកសងខ្លួន យោងទៅលើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី...........ខែ.......ឆ្នាំ.......ដែលមានភាគីម្ចាស់បណ្តឹង ជាម្ចាស់បំណុល និងភាគីចុងចម្លើយជាកូនបំណុល។ នេះជាឧទាហរណ៍ដែលបានបញ្ជាក់ពីការទាមទារឲ្យសងប្រាក់ដោយម្ចាស់បណ្តឹង សំអាងលើកិច្ចសន្យាខ្ចីប្រាក់ដែលខ្លួនបានធ្វើ ជាមួយភាគីចុងចម្លើយ ដោយបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាឡើង។ ក្រៅពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ភាគីគប្បីសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារផងដែរ ប៉ុន្តែគប្បីសរសេរនូវចំណុចអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ ដាច់ដោយឡែកពីគ្នា។ យ៉ាងណាមិញ នៅពេលដែលពាក្យបណ្តឹង មានសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺស្របទៅនឹងលក្ខខណ្ឌនៃមាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ ហេតុនេះហើយ តុលាការមិនត្រូវលើកពាក្យបណ្តឹងនោះចោលទេ។

## ផ្នែកទី២.ចំណុចដែលគួរគប្បីសរសេរក្នុងពាក្យបណ្តឹង

ក្រៅពីចំណុចដែលត្រូវសរសេរ[១៣]ក្នុងពាក្យបណ្តឹង ដែលមានចែងនៅក្នុងមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏នៅមានចំណុចដែលដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង។ ដូចនេះ ដើម្បីសិក្សាឱ្យស៊ីជម្រៅលើចំណុចអង្គហេតុដែលជាមូលហេតុនៃការទាមទារនេះ យើងត្រូវដឹងជាមុនអំពីភាពខុសគ្នារវាងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ។ការសរសេរអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ នៅក្នុងពាក្យបណ្តឹង គឺដើម្បីបែងចែកឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹង ពីការទាមទារដទៃទៀត។

ឧទាហរណ៍៖ ដើមចោទ បានទាមទារឱ្យចុងចម្លើយ សងប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង ហើយគេអាចបញ្ជាក់ឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទបានតាមរយៈ ការបញ្ជាក់ឱ្យបានច្បាស់លាស់នូវប្រធាននៃសិទ្ធិ , កម្មវត្ថុនៃសិទ្ធិ , ប្រភេទនៃសិទ្ធិ , ខ្លឹមសារនៃសិទ្ធិ និង មូលហេតុនៃការកកើតសិទ្ធិ។

### ២.អង្គហេតុដែលជាមូលហេតុនៃការទាមទារ

រីឯការសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារ នៅក្នុងពាក្យបណ្តឹង គឺដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។ ឧទាហរណ៍៖ ដើមចោទ បានទាមទារឱ្យចុងចម្លើយ សងប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង ដោយបានបញ្ជាក់បន្ថែមថា ដើមចោទ បានប្រគល់ប្រាក់ឱ្យចុងចម្លើយនៅក្នុងចំនួនកំណត់ណាមួយ ដោយកាលកំណត់សងត្រូវបានកន្លងផុតទៅហើយ។ ដូច្នេះ អង្គហេតុទាំងនេះ អាចអះអាងអំពីការកកើតសិទ្ធិតាមក្រមរដ្ឋប្បវេណីបាន។

ម៉្យាងទៀត ករណីដែលនៅក្នុងពាក្យបណ្តឹងមានសរសេរអំពីអង្គហេតុទាំងពីរខាងលើនេះជាន់គ្នា គឺមានច្រើនណាស់។ ប៉ុន្តែ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺមានលក្ខណៈសំខាន់ជាងអង្គហេតុដែលជា

---

[១៣] មាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

មូលហេតុនៃការទាមទារ ពីព្រោះថា ប្រសិនបើនៅក្នុងពាក្យបណ្តឹង មិនមានសរសេរអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនោះទេ តុលាការអាចចេញដីកាសម្រេចលើកពាក្យបណ្តឹងនោះចោលបាន។ ផ្ទុយមកវិញ ប្រសិនបើនៅក្នុងពាក្យបណ្តឹង មិនមានសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះទេ តុលាការមិនអាចចេញដីកាសម្រេចលើកពាក្យបណ្តឹងនោះចោលបានទេ។

យ៉ាងណាមិញ ការសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារ នៅក្នុងពាក្យបណ្តឹង នៅតែជាចំណុច ឬ អង្គហេតុដែលមានអត្ថប្រយោជន៍ចំពោះដំណើរការនៃនីតិវិធីរបស់តុលាការ ដូចជា អាចបង្កភាពងាយស្រួលដល់តុលាការ ក្នុងការរៀបចំចំណុចវិវាទ ចាប់តាំងពីពេលដែលចាប់ផ្តើមកាលបរិច្ឆេទនៃការជំនុំជម្រះក្តីលើកដំបូង និង តុលាការអាចចេញសាលក្រមកំបាំងមុខបាន ប្រសិនបើចុងចម្លើយអវត្តមាន ដោយពុំចាំបាច់ធ្វើការបញ្ជូនជាថ្មីនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមចោទ ទៅចុងចម្លើយតាមមាត្រា២០២ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត ក្នុងពាក្យបណ្តឹង ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដោយអានត្តិ ព្រមទាំងលេខទូរស័ព្ទ(រួមទាំងលេខទូរសារ) ជាអាទិ៍ របស់ដើមចោទ ឬអ្នកតំណាងដោយអាណត្តិនោះ។លើសពីនេះ ដើម្បីឲ្យអាចដឹកនាំបណ្តឹងឲ្យទាន់ពេលវេលា ចាំបាច់ត្រូវមានភ្ជាប់ក្នុងពាក្យបណ្តឹងនេះ នូវសេចក្តីចម្លងភស្តុតាងជាឯកសារសំខាន់ៗជាអាទិ៍ផងដែរ។ជាទូទៅ ចំណុចក្រៅពីចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ គេហៅថា ចំណុចដែលត្រូវសរសេរដោយស្ម័គ្រចិត្ត ។

## ២.១.. អង្គហេតុសំខាន់ៗដែលទាក់ទងនឹងការទាមទារ(អង្គហេតុប្រយោល)

នៅក្នុងចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹងនេះ នៅមានចំណុចសំខាន់ដែលដើមចោទគប្បីសរសេរ ឬ ដកស្រង់មកដាក់នៅក្នុងពាក្យបណ្តឹងទៀតនោះគឺ អង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង។ អង្គហេតុសំខាន់ៗនោះ អាចជាអង្គហេតុប្រយោល ដែលជាអង្គហេតុទាំងឡាយណាដែលអាចធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង ដែលជាអង្គហេតុផ្ទាល់។ ដោយអង្គហេតុនេះត្រូវបញ្ជាក់ដោយភស្តុតាង ហើយដើម្បីបញ្ជាក់នូវភស្តុតាងនៃអង្គហេតុនេះ គេបានបែងចែងវិធីដើម្បីបញ្ជាក់ភស្តុតាងនៃអង្គហេតុចេញជាពីរគឺ៖

- ការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុនោះ ដោយភស្តុតាងផ្ទាល់។
- ការទទួលស្គាល់នូវអង្គហេតុប្រយោល តាមរយៈភស្តុតាងប្រយោល ហើយទទួលស្គាល់នូវអង្គហេតុនោះ ដោយអង្គហេតុប្រយោលដែលបានបញ្ជាក់នេះ ដូចនេះគឺជាការសន្និដ្ឋាននូវអង្គហេតុនោះ តាមរយៈអង្គហេតុប្រយោល។

ប្រសិនបើភស្តុតាងមានមិនគ្រប់គ្រាន់សម្រាប់ធ្វើការបញ្ជាក់លើអង្គហេតុចម្បងនោះទេ ដើមចោទគប្បីសរសេរក្នុងពាក្យបណ្តឹងនូវអង្គហេតុប្រយោលឱ្យបានច្រើន។ ប៉ុន្តែប្រសិនបើមាននូវភស្តុតាងផ្ទាល់ដែលច្បាស់លាស់ស្រាប់ហើយ មិនចាំបាច់សរសេរអង្គហេតុប្រយោលក៏បានដែរ។ ឧទាហរណ៍៖ **លោក ក** បានឱ្យប្រាក់ **លោក ខ** ខ្ចីប្រាក់ចំនួនកំណត់ ហើយ **លោក ក** បានអះអាងថាគាត់បានដកប្រាក់ពីធនាគារតាមប្រាក់ដែលបានកំណត់ឱ្យខ្ចីនោះ មុនពេលឱ្យ **លោក ខ** ខ្ចី ហើយបន្ទាប់ពី **លោក ខ** បានទទួលប្រាក់ដែលខ្ចីនោះហើយ **លោក ខ** បានយកប្រាក់នោះទៅទិញរថយន្តមួយគ្រឿងដែលមានតម្លៃប្រហាក់ប្រហែលនឹងចំនួនប្រាក់ដែលបានខ្ចីនោះ។ ដូច្នេះហើយអង្គហេតុដែលបានរៀបរាប់នៅក្នុងឧទាហរណ៍នេះ គឺជាអង្គហេតុប្រយោល។

➢ **រឿងក្តីចំនួនទឹកប្រាក់តិច**

គោលគំនិតនៃការបង្កើតនីតិវិធីនៃរឿក្តីចំនួនទឹកប្រាក់តិច គឺជាការបង្កើតនូវនីតិ វិធីដោះស្រាយឲ្យបានងាយស្រួល និងឆាប់រហ័ស នូវវិវាទស្តីពីការបង់ទឹកប្រាក់ចំនួនតិច ដែលកើតច្រើននៅក្នុងជីវភាពសង្គមប្រជាពលរដ្ឋរស់នៅ ដើម្បីឲ្យប្រជាពលរដ្ឋធម្មតា អាចយករឿងក្តីដែលជាប់ជិតស្និទ្ធនឹងជីវភាពរបស់ខ្លួនឡើងតុលាការ និងទទួលបានការ សង្គ្រោះសិទ្ធិរបស់ខ្លួន (មាត្រា ២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ រឿងក្តីដែលអាចប្រើ នីតិវិធីក្តីចំនួនទឹកប្រាក់តិចបានគឺរឿងក្តីដែលមានគោលបំណងទាមទារឲ្យបង់ជា ប្រាក់ដែលចំនួនទឹកប្រាក់នៃកម្មវត្ថុនៃបណ្តឹងនោះ មិនលើសពី ១ (មួយ)_ លានរៀល ឡើយ (មាត្រា ២២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

➢ **បញ្ញត្តិពិសេសស្តីពីការការសរសេរ និងដាក់ពាក្យបណ្តឹង**

ការដាក់ពាក្យបណ្តឹងក្នុងរឿងក្តីទឹកប្រាក់តិច អាចធ្វើជាលក្ខ័អក្សរ តាមមាត្រ ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬធ្វើដោយផ្ទាល់មាត់ ក៏បាន មាត្រា ២២៥ កថាខណ្ឌទី១ នៃក្រម នីតិវិធីរដ្ឋប្បវេណី ។ ក្នុងករណីបណ្តឹងធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជី ត្រូវកត់ត្រានូវ សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ដើមចោទក្នុងកំណត់ហេតុ ហើយកំណត់ហេតុ នេះ ត្រូវបានចាត់ទុកជាពាក្យបណ្តឹង_(មាត្រា ២២៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋ ប្បវេណី) ។ ការធ្វើដូចនេះ គឺដើម្បីឲ្យប្រជាជនដែលមិនចេះអក្សរ ក៏អាចទាមទារឲ្យតុលាការការពារសិទ្ធិរបស់ខ្លួនបាន ។

➢ **នីតិវិធីនៃការលើកបណ្តឹងចោល**

ជាដំបូងបណ្តឹងត្រូវដាក់ចូលទៅកាន់ការិយាល័យរបស់ក្រឡាបញ្ជីនៃសាលាដំបូង រាជធានីខេត្តដែលមានសមត្ថកិច្ច។ក្រឡាបញ្ជីមានភារកិច្ចទទួលពាក្យបណ្តឹង និងក៏ជា អ្នករៀបចំសំណុំរឿងទាំងនេះផងដែរ។ យ៉ាងណាមិញក្រឡាបញ្ជីក៏អាចប្រាប់ដល់ដើម បណ្តឹងឲ្យធ្វើការកែតម្រូវនូវពាក្យបណ្តឹង ល្ពឹកណាក្នុងករណីវាមានការខ្វះខាតពេលគឺ ពាក្យបណ្តឹងពុំបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងចំនុច ក និង ខ នៃ

ក្រមនីតិវិធី រដ្ឋប្បវេណីកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយក៏ខ្លួនមិនមានសិទ្ធិពិសេសណាមួយក្នុង ការបដិសេធនូវបណ្តឹងដែលនាំយកមកនោះទេ។នីតិវិធីនៃការលើកបណ្តឹងចោលតុលាការប្រតិបត្តិការតាមរយៈដីការសម្រេច និង សាលក្រម ។ហើយមានមូលហេតុ ឬករណីបីយ៉ាងដែលនាំឲ្យឈានដល់ការលើកបណ្តឹង ចោល មូលហេតុទាំងនោះមានដូចខាងក្រោម៖

(ក្នុងករណីពាក្យបណ្តឹងមានការខ្វះខាតមិនអាចបញ្ជូនដល់ចុងចម្លើយបាន) នៅពេលដែលបណ្តឹងបានមកដល់ក្នុងដៃរបស់ចៅក្រមដែលមានសមត្ថកិច្ច ហើយ លោកពិនិត្យឃើញថាពាក្យបណ្តឹងនោះមានលក្ខណៈខ្វះចន្លោះដែលពុំទាន់បានគោរព តាមមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ។ ដូច្នោះចៅក្រមអាចដាស់តឿនដើម បណ្តឹងឲ្យធ្វើការកែតម្រូវតាមរយៈផ្ទាល់មាត់ ទូរស័ព្ទ ឬក៏តាមរយៈលិខិតរដ្ឋបាលជាលា យលក្ខ័អក្សរជាដើម ។ តែបើនៅមិនព្រមកែតម្រូវទៀតលោកអាចដីការដាស់តឿន ដោយកំណត់កំឡុងពេលជាក់លក្ខណាមួយឲ្យម្ចាស់បណ្តឹងកែតម្រូវ (មាត្រា៧៨នៃក្រមនីតិ(វិធីរដ្ឋប្បវេណីកម្ពុជា២០០៧។ បន្ទាប់មកក្នុងករណីដើមបណ្តឹងនៅតែមិនបំពេញ ទៀតនោះតុលាការ នឹងចេញដីការសម្រេចលើកបណ្តឹងនោះចោល ហើយមានការជូន ដំណឹងដល់ម្ចាស់បណ្តឹងជាដាច់ខាត ពោលដើម្បីទុកពេលឲ្យដើមបណ្តឹងទទួលបានសិទ្ធិ ជាសារវន្តក្នុងការប្តឹងឧបាស្រ័យ។

ឧទាហរណ៍ ៖ ដើមចោទលោក A បានប្តឹងសុំទាមទារប្រាក់ពី ចុងចម្លើយលោក B ចំនួន ១000 ដុល្លារអាមេរិក ហើយតុលាការបានធ្វើការពិនិត្យលើកបណ្តឹងរបស់ដើម ចោទ ឃើញថា ពុំបានបញ្ជាក់ពីអាសដ្ឋាយរបស់ចុងចម្លើយលោក B នោះទេ ។នីតិវិធីនៃការសរសេរពាក្យបណ្តឹងរដ្ឋប្បវេណី ក្នុងករណីនេះ តុលាយល់ឃើញថា បណ្តឹងរបស់ដើមចោទលោក A ពុំបានសរ សេរពេញលេញតាមលក្ខណ្ឌដូចមានចែងក្នុងចំណុច ក និង ខ (មាត្រា ៧៥ កថាខណ្ឌ ១ និង ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយសារពុំបានបញ្ជាក់ពីអាសដ្ឋាយរបស់ចុងចម្លើយ លោក B ហើយវាជាចំណុកមួយដែលមិនអាចឲ្យតុលាការធ្វើការកោះហៅ ចុងចម្លើយ លោក B បាននោះទេ ដូច្នេះតុលាការនិងអាចបង្គាប់ឲ្យដើមចោទលោក A កែតម្រូវ នៅពាក្យបណ្តឹងរបស់ខ្លួន ដោយកំណត់ពីពេលវេលានៃការកែតម្រូវលើបណ្តឹងនោះ ហើយបើក្នុងករណីដើមចោទលោក_A_ ពុំព្រមធ្វើការកែតម្រូវតាមការបង្គាប់របស់ តុលាការនោះ ចៅក្រម គឺមានសិទ្ធិលើកបណ្តឹងលោក A ចោល ដោយចេញដីកាសម្រេច លើបណ្តឹងចោល (តាមមាត្រ ៧៨ កថាខណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ក្នុងករណីមិនបានបង់ប្រាក់ប្រដាប់ក្តី ការមិនបានបង់ប្រាក់ប្រដាប់ក្តីក៏ជាមូលហេតុមួយដែលធ្វើឲ្យតុលាការលើកបណ្តឹង នោះចោលដែរ។នៅពេលបណ្តឹងដែលដាក់មកហើយតុលាការពិនិត្យឃើញថា ម្ចាស់ បណ្តឹងមិនបានបំពេញកាតព្វកិច្ចក្នុងការបង់ប្រាក់ប្រដាប់ក្តីទេ តុលាការត្រូវបង្គាប់ឲ្យ ដើមចោទបង់ប្រាក់ប្រដាប់ក្តីដែលច្បាប់បានកំណត់សិន។ បើពុំដូច្នោះទេ តុលាការនឹង លើកបណ្តឹងនោះចោលដោយដីការសម្រេចដែរ (មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ម្យ៉ាងវិញទៀតដីការសម្រេចនេះបើកផ្លូវឲ្យមានការប្តឹងទាស់បាន ។

ក្នុងករណីបណ្តឹងជួយច្បាប់ និងចំនុចខ្វះខាតមិនអាចកែប្រែបាន រាល់បណ្តឹងដែលដាក់មកតុលាការ ចាំបាច់កម្មវត្ថុនៃការទាមទារឲ្យតុលាការចេញ សាលក្រមនោះត្រូវតែស្របច្បាប់ដាច់ខាត គោលការណ៍សុចរិត្តនិងស្មោះត្រង់

របស់គូរ ភាគី។ ក្នុងករណីកម្មវត្ថុនៃការទាមទារនោះវាមានលក្ខណៈខុសច្បាប់ ឬក្នុងលក្ខខណ្ឌមានចំនុចខ្វះខាតដែលមិនអាចកែប្រែនូវបណ្តឹងនោះបានទេតុលាការនិងលើកបណ្តឹងនេះ ចោលដោយសាលក្រម ពោលគឺមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលផ្ទាល់មាត់ឡើ (មាត្រា៨១នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា២០០៧)។

ឧទាហរណ៍ ៖ Aបានប្តឹងទាមទារឲ្យសងប្រាក់ថ្លៃទិញអាវុធម៉ាក AK C127ពីរដើម ក្នុងតម្លៃ២០០០ដើម។ នីតិវិធីនៃការសរសេរពាក្យបណ្តឹងរដ្ឋប្បវេណី ចំណែកឯបណ្តឹងជួយច្បាប់វិញគឺសំដៅកំហុសខាងផ្នែកនីតិវិធី ហើយកំហុសនេះ ត្រូវបានចៅក្រមត្រួតពិនិត្យរហូតចេញសាលក្រម។ ឧទាហរណ៍៖ បណ្តឹងដែលមានលក្ខណៈផ្ទុយនឹងច្បាប់មានដូចខាងក្រោម៖ » អសមត្ថកិច្ចក្នុងការជំនុំជម្រះរបស់តុលាការកម្ពុជា » កង្វះលក្ខណៈជាភាគី » អសមត្ថកិច្ចរបស់តុលាការទទួលពាក្យបណ្តឹង ជាដើម ។ល។បើក្នុងករណីនេះ នោះតុលាការនឹងលើកបណ្តឹងនោះចោលដោយសាល ក្រមដូចទៅដូចបណ្តឹងដែលមានកម្មវត្ថុខុសច្បាប់ដែរ។

## ២.២.ភស្តុតាង

ភស្តុតាង គឺជាតឹកតាងជាលាយល័ក្ខអក្សរ ឬមិនលាយល័ក្ខអក្សរពាក់ព័ន្ធនឹងចំណុចវិវាទគូភាគីដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។ភស្តុតាងមាន៥ប្រភេទ គឺ៖

### ២.១.២.១. ការសាកសួរសាក្សី

សាក្សី គឺជាតតិយជនដេលត្រូវតុលាការបង្គាប់ឲ្យធ្វើសេចក្តីរាយការណ៍ជូនតុលាការ ស្តីពីអង្គហេតុនៃអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯង នៅក្រៅបណ្តឹង។ជនដែលត្រូវបានកោះហៅជាសាក្សី មានករណីកិច្ចត្រូវបង្ហាញខ្លួនចំពោះមុខតុលាការ ជាគោលការណ៍ គឺត្រូវធ្វើសម្បថ ហើយត្រូវឆ្លើយជាកស្សិណសាក្សី ( មាត្រា១៣៧)[១៤]។តុលាការអាចបង្គាប់ឲ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវដោយដីកាសម្រេចបាន(មាត្រា១៣២ ក.២)[១៥]។

ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី១.០០០.០០០រៀល[១៦] ដោយដីកាសម្រេចបាន(មាត្រា ១៣២ក.២)។ មុនពេលសាកសួរតុលាការត្រូវឲ្យសាក្សីធ្វើសម្បថ ដោយពន្យល់អំពីគោលបំណងនៃសម្បថហើយប្រាប់ឲ្យដឹងជាមុនអំពីការផ្តន្ទាទោស ក្នុងករណីផ្តល់សក្ខីភាពក្លែងក្លាយ[១៧](មាត្រា១៣៧)។

---

[១៤] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[១៥] មាត្រា ១៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[១៦] មាត្រា ១៣២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[១៧] មាត្រា ១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**ក.នីតិវិធីនៃការសាកសួរសាក្សី**

- ការស្នើសុំសួរសាក្សី ត្រូវកំណត់ឲ្យបានច្បាស់លាស់ទៅលើសាក្សីណាមួយ
- ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសួរ
- ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់ គឺប្រធានក្រុមប្រឹក្សាជំនុំជម្រះភាគីដែលបានស្នើសុំឲ្យសាកសួរនោះ និងភាគីម្ខាងទៀត។
- សាក្សីមិនអាចឆ្លើយដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ
- សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ២សប្តាហ៍មុនថ្ងៃសាកសួរ។

➢ **ដីកាកោះហៅត្រូវសរសេរនូវកំណត់សម្គាល់ដូចខាងក្រោមៈ**

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី

ខ. ពេលវេលា និង ទីកន្លែងដែលត្រូវចូលខ្លួន

គ. ទណ្ឌកម្មដែលកំណត់ដោយច្បាប់ នឹងកើតមានមិនចូលខ្លួន

**២.១.២.២. ការសាកសួរភាគី**

ការសាកសួរភាគី គឺជាការពនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការ ដើម្បីទទួលនូវភស្តុតាងដោយយក សាមីភាគីមកធ្វើជាភស្តុតាង ដោយឲ្យធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់នោះ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ការសាកសួរភាគី គឺជានីតិវិធីដែលមានគោលបំណងទទួលយកនូវធនធានភស្តុតាង ដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ភាគីក្នុងការសាកសួរភាគីនេះ គឺជាធនធានភស្តុតាង ហើយមានអត្ថន័យខុសគ្នានឹងការអះអាងរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ឧទាហរណ៍ៈ នៅក្នុងការសាកសួរភាគីទោះជាភាគីបានថ្លែងការណ៍ស្របទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ដែលធ្វើឲ្យខូចប្រយោជន៍របស់ខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍នោះមិនមែនក្លាយទៅជាការសារភាពតាមផ្លូវបណ្តឹងទេ គឺការថ្លែងការណ៍នោះគ្រាន់តែជាធនធានភស្តុតាងមួយដែលចៅក្រមនឹងធ្វើការវាយតម្លៃដោយជំនឿទុកចិត្តរបស់ខ្លួនប៉ុណ្ណោះ។ ម្យ៉ាងទៀតផ្ទុយទៅវិញក្រោមការណ៍នៃការទាញហេតុផល ទោះជាធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុណាមួយនៅពេលសាកសួរភាគីក៏ដោយ តែប្រសិនបើមិនបានអះអាងក្នុងការទាញហេតុផលរបស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាហេតុផលរបស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាអះអាងក្នុងការទាញហេតុផល

របស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាជាធនធានសម្រាប់ធ្វើការវិនិច្ឆ័យក្នុងការចេញសាលក្រមបានឡើយ។

ម៉្យាងទៀត ផ្ទុយទៅវិញក្រោមការណ៍នៃការទាញហេតុផល ទោះជាធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុណាមួយនៅពេលសាកសួរភាគីក៏ដោយ តែប្រសិនបើមិនបានអះអាងក្នុងការទាញហេតុផលរបស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាហេតុផលរបស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាអះអាងក្នុងការទាញហេតុផលរបស់ភាគីទេតុលាការមិនអាចយកមកគិតពិចារណាជាធនធានសម្រាប់ធ្វើការវិនិច្ឆ័យក្នុងការចេញសាលក្រមបានឡើយ។នីតិវិធីដើម្បីយកសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដែលច្បាប់បានកំណត់របស់អសមត្ថជនក្នុងការធ្វើបណ្តឹងដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាល ជាដើម(អ្នកមានអំណាចមេបា. អ្នកអាណាព្យាបាល)ឬអ្នកតំណាងដែលតំណាងឲ្យនីតិបុគ្គល(នាយកប្រតិបត្តិសហគ្រាស ជាដើម) មកធ្វើជាធនធានភស្តុតាងមិនមែនត្រូវធ្វើជាការសាកសួរសាក្សីទេ គឺត្រូវធ្វើតាមនីតិវិធីសាកសួរភាគី ដោយចាត់ទុកថា ជនទាំងនោះមានលក្ខណៈប្រហាក់ប្រហែលនឹងសាមីភាគីដែរ(មាត្រា១៤២)[១៨]។តុលាការអាចធ្វើការសាកសួរភាគី និងឲ្យភាគីស្បថបានក្នុងករណីដែលធ្វើការសាកសួរភាគី បើភាគីពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ[១៩] ឬផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន(មាត្រា១៤០ក.២)។បើភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី២.០០០.០០០រៀលបានដោយដីកាសម្រេច[២០](មាត្រា១៤០ ក.៣)។ការសាកសួរភាគី គឺអនុវត្តដូចគ្នាទៅនឹងការសាកសួរសាក្សីដែរ(មាត្រា១៤១ក.១)។ បើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើការសាកសួរសាមីភាគី ជាមួយនឹងភាគីម្ខាងទៀត ឬជាមួយសាក្សីបាន នៅពេលជាមួយគ្នា(មាត្រា១៤១ក.២)។

### ២.១.២.៣. កោសលវិច័យ

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឲ្យតតិយជន(អ្នកជំនាញកោសលវិច័យ)ដែលមានចំណេះវិជ្ជា និងបទពិសោធន៍ពិសេស ឲ្យធ្វើរបាយការណ៍អំពីការវិនិច្ឆ័យ ឬយោបល់ដែលបានមកពីការអនុវត្តវិធានតាមបទពិសោធន៍ជំនាញ ចំពោះអង្គហេតុជាក់ស្តែងដែលជាបញ្ហានៅក្នុងបណ្តឹងនោះ។តុលាការជាអ្នកកំណត់អ្នកជំនាញខាងកោសលវិច័យ[២១](ម.១៤៤ ក.១)។

[១៨] មាត្រា ១៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[១៩] មាត្រា ១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២០] មាត្រា ១៤០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ជនដែលមានចំណេះដឹង នឹងបទពិសោធន៍មានករណីកិច្ចធ្វើកោសលវិច័យ(មាត្រា១៤៤.ក២)។តុលាការមិនអាចបង្គាប់ឲ្យនាំខ្លួនអ្នកជំនាញកោសលវិច័យនោះ ចូលតុលាការដូចសាក្សីទេ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមានហេតុរាំងដល់សច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងផាត់ចោលកោសលវិច័យនោះបាន[២២](មាត្រា១៤៥)។

មានន័យថា ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើងត្រឹមត្រូវ[២៣](មាត្រា១៥៥ កថាខណ្ឌទី១)។ស្តីពីការបញ្ជាក់នូវភាពត្រឹមត្រូវនៃការបង្កើតឯកសារវិញ ដូចដែលពន្យល់ខាងក្រោមនេះ គឺឯកសារអាចចែកជាពីរប្រភេទ គឺជាឯកសារសាធារណៈ និង ឯកសារឯកជន ហើយត្រូវបានបញ្ញត្តិខុសគ្នា ទៅតាមប្រភេទនៃឯកសារនោះ។

### ២.១.២.៤. ភស្តុតាងជាឯកសារ

លិខិត ឬឯកសារជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងអង្គហេតុណាមួយនៃរឿងក្តីអាចជាភស្តុតាងយ៉ាងសំខាន់សម្រាប់ចៅក្រមក្នុងការសម្រេចសេចក្តី។ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើដោយផ្តល់ឯកសារដែលសាមីភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឲ្យបង្គាប់ដល់ម្ចាស់ឯកសារផ្តល់ឯកសារនោះមក[២៤](មាត្រា១៤៨ ក.១)។ក្នុងករណីដែលយល់ឃើញថាចាំបាច់ អាចឃាត់ទុកនូវឯកសារដែលផ្តល់មកនោះបាន (មាត្រា ១៤៨ ក.២)។

#### ប្រភេទនៃឯកសារ៖

#### (ក).ឯកសារជាសាធារណៈ និងឯកសារឯកជន

ឯកសារដែលធ្វើឡើងដោយមន្ត្រីរាជការក្នុងការបំពេញមុខនាទីរបស់ខ្លួន ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន(ឧទាហរណ៍ដូចជា មូលសាលក្រម,កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់,ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃបញ្ជីអាត្រានុកូលដ្ឋាន,ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃសៀវភៅគោលបញ្ជីដីធ្លី ជាអាទិ៍ គឺជាឯកសារជាសាធារណៈ ហើយឯកសារក្រៅពីនេះ គឺជាឯកសារឯកជន។

---

[២១] មាត្រា១៤៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២២] មាត្រា ១៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៣] មាត្រា ១៥៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៤] មាត្រា ១៤៨ កថាខណ្ឌទី ១និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចំពោះឯកសារសាធារណៈ បើទទួលស្គាល់តាមទម្រង់ និងខ្លឹមសារនៃឯកសារនោះត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ ត្រូវបានសន្មត[25](មាត្រា១៥៥ កថាខណ្ឌទី២) ហេតុនេះហើយ អ្នកស្នើសុំឲ្យពិនិត្យឯកសារនោះ មិនចាំបាច់ធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះទេ(ក្នុងករណីដែលមានការសង្ស័យអំពីភាពត្រឹមត្រូវក្នុងការបង្កើតឯកសារសាធារណៈ។ផ្ទុយទៅវិញ ចំពោះឯកសារឯកជន ចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ ក៏ប៉ុន្តែប្រសិនបើនៅក្នុងឯកសារឯកជននោះ ត្រូវបានសន្មត[26](មាត្រា១៥៥ កថាខណ្ឌទី៤)។ ដូច្នេះហើយភាគីម្ខាងទៀតដែលធ្វើវិវាទអំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារឯកជនបែបនេះ ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើង ដោយខុសពីឆន្ទៈរបស់អ្នកដែលបានធ្វើឯកសារ។

(**ខ**).**ឯកសារចាត់ចែង និង ឯកសាររបាយការណ៍**

ក្នុងករណីដែលមានសកម្មភាពគតិយុត្ត ជាដើម ដោយឯកសារ(ដូចជា មតកសាសន៍ រូបិយាណត្តិ លិខិតកិច្ចសន្យា ជាដើម) ឯកសារនោះត្រូវហៅថាជាឯកសារចាត់ចែង។ ឯកសារក្រៅពីនេះ ដូចជាវិក័យប័ត្រ សំបុត្រពេទ្យ សំបុត្រ កំណត់ប្រចាំថ្ងៃ កំណត់ហេតុជាដើម របស់អ្នកធ្វើឯកសារ គេហៅថា ឯកសាររបាយការណ៍។ ចំពោះឯកសារចាត់ចែង ប្រសិនបើបានបញ្ជាក់ពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះហើយ សកម្មភាពគតិយុត្ត ដែលមានខ្លឹមសារនៅក្នុងឯកសារនោះ ក៏ត្រូវបានបញ្ជាក់ថា ត្រូវបានធ្វើឡើងដែរ។ចំពោះឯកសាររបាយការណ៍វិញ ទោះជាបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះក៏ដោយ ក៏សមត្ថភាព/អំណាចជាសារធាតុនៃភស្តុតាង មានការគ្នាទៅតាមខ្លឹមសារនៃការសរសេរក្នុងឯកសារនោះ។

(គ).**ច្បាប់ដើម(ឯកសារដើម) ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់**

ច្បាប់ដើម(ឯកសារដើម) គឺមានន័យថា ជាសំណៅដើម ឬឯកសារពិត។រីឯឯកសារចម្លងដែលមានសេចក្តីបញ្ជាក់វិញ គឺជាឯកសារដែលបានចម្លងតាមខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) ទាំងស្រុងតែម្តង ហើយដែលជាឯកសារបញ្ជាក់អំពីអត្ថិភាព ព្រមទាំងខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម)នោះ។ រីឯឯកសារយថាភូតវិញ គឺជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលបានធ្វើឡើងដើម្បីឲ្យមានអានុភាពតាមផ្លូវច្បាប់ដូចច្បាប់ដើម(ឯកសារដើម)ដែរ។

[25] មាត្រា១៥៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[26] មាត្រា១៥៥ កថាខណ្ឌទី៤

**ឧទាហរណ៍៖ ក្នុងការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្ត នៃលិខិតអនុវត្តផងដែរ(មាត្រា ៣៤៩ កថាខណ្ឌទី២)។**

### (ក).ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល

ភស្តុតាងផ្ទាល់គឺជាភស្តុតាងដែលបញ្ជាក់ដោយផ្ទាល់ អំពីអត្ថិភាព ឬនត្ថិភាព នៃអង្គហេតុផ្ទាល់(អង្គហេតុចម្បង)ដែលឆ្លើយតបទៅនឹងលក្ខខ័ណ្ឌផ្ទាល់នៃអានុភាពគតិយុត្ត គឺការបង្កើត ការផ្លាស់ប្តូរ ឬការរំលត់សិទ្ធិ និងកាតព្វកិច្ច។ឧទាហរណ៍ នៅក្នុងករណីនៃបណ្តឹងដែល A ប្តឹងទាមទារឲ្យ B សងប្រាក់កម្ចីចំនួន១០ លានរៀលដែលខ្លួនបានឲ្យ B ខ្ចីលិខិតនៃកិច្ចសន្យាខ្ចីបរិភោគ និងសាក្សីដែលបានមានវត្តមាននៅកន្លែងធ្វើកិច្ចសន្យា គឺជាភស្តុតាងផ្ទាល់ដែលបញ្ជាក់អំពីអង្គហេតុនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ។

ភស្តុតាងប្រយោល គឺជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុប្រយោល និងអង្គហេតុបន្ទាប់បន្សំ ដែលមានប្រយោជន៍ក្នុងការបញ្ជាក់អំពីអង្គហេតុផ្ទាល់។

ក្នុងករណីដែលពុំមានភស្តុតាងផ្ទាល់ទេចាំបាច់ត្រូវបញ្ជាក់អំពីអង្គហេតុប្រយោល ដោយផ្អែកលើភស្តុតាងប្រយោល ហើយត្រូវបញ្ជាក់អំពីអង្គហេតុផ្ទាល់ ដោយធ្វើការសន្និដ្ឋានអំពីអង្គហេតុផ្ទាល់ តាមរយៈការអនុវត្តរូបមន្តនៃបទពិសោធន៍(វិធានតាមបទពិសោធន៍)។អង្គហេតុបន្ទាប់បន្សំ គឺជាអង្គហេតុស្តីពីលក្ខណសម្បត្តិតាមផ្លូវច្បាប់ដែលអាចយកទៅប្រើជាភស្តុតាងបាន(អំណាច ឬសមត្ថភាពជាភស្តុតាង) ឬអង្គហេតុស្តីពីអានុភាពដែលជួយឲ្យចៅក្រមមានការជឿជាក់ទៅលើអ្វីមួយ(តម្លៃជាភស្តុតាង)។

**ឧទាហរណ៍៖អង្គហេតុបន្ទាប់បន្សំ មានដូចជាអង្គហេតុស្តីពីភាពគួរឲ្យជឿបាននៃសេចក្តីថ្លែងការណ៍របស់សាក្សី ឬអង្គហេតុស្តីពីបញ្ហាថាតើឯកសារណាមួយត្រូវបានបង្កើតឡើង ដោយត្រឹមត្រូវដែរ ឬទេ(មាត្រា១៥៥)។**

### ២.១.២.៥. ការត្រួតពិនិត្យ

ការស្នើសុំត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាងដោយការត្រួតពិនិត្យនូវភិនភាគ ដោយចៅក្រមប្រើនូវវិញ្ញាណទាំងប្រាំរបស់ខ្លួនគឺ ចក្ខុវិញ្ញាណ, សោតវិញ្ញាណ,កាយវិញ្ញាណ,ឃានវិញ្ញាណ, និងជិវ្ហាវិញ្ញាណ។ហើយកម្មវត្ថុ ឬមននុស្សដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះ គេហៅថា **វត្ថុដែលត្រូវត្រួតពិនិត្យ។**

# ជំពូកទី២

# ប្រភេទនៃពាក្យបណ្តឹង

## ផ្នែកទី១. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

### ៣.. អត្ថន័យនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងមួយដែលទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកតាមផ្លូវច្បាប់សារធាតុដែលបានកំណត់នៅក្នុងការទាមទារតាមផ្លូវបណ្តឹង។ ចំណែកឯខ្លឹមសារនៃតាវកាលិកវិញតាមធម្មតា ក្រៅពីការបង់ប្រាក់កំណត់មួយ ដូចជាការទាមទាររបស់ដើមចោទ អាចមានករណីជាច្រើនដូចជា ការទាមទារឱ្យប្រគល់អចលនវត្ថុ ការទាមទារឱ្យប្រគល់ចលនវត្ថុ និង ការទាមទារឱ្យធ្វើសកម្មភាពណាមួយ ឬការទាមទារមិនឱ្យធ្វើសកម្មភាពណាមួយ។ ឧទាហរណ៍៖ **លោក ក** ជាម្ចាស់បំណុល និង **លោក ខ** ជាកូនបំណុល បានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា ហើយនៅពេលដែលកាលកំណត់នៃថ្ងៃសងប្រាក់ត្រូវបានមកដល់ ប៉ុន្តែ **លោក ខ** មិនព្រមសងប្រាក់នោះមកឱ្យ **លោក ក** វិញឡើយ។ ដូចនេះ **លោក ក** ក៏បានដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទាមទារប្រាក់កម្ចីពី **លោក ខ** ត្រឡប់មកវិញ ដោយក្នុងពាក្យបណ្តឹង **លោក ក** បានសរសេរទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ **លោក ខ** ដែលជាកូនបំណុលបង់ប្រាក់ដើម និង ការប្រាក់ដែលច្បាប់បានកំណត់មកឱ្យខ្លួន។ ក្នុងករណីដែល **លោក ក** បានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឱ្យ **លោក ខ** បង់ប្រាក់ដើម និង ការប្រាក់ដែលច្បាប់បានកំណត់នេះ គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក។

### ៣.១.. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាបណ្តឹង ដែលដើមចោទ បានដាក់ឡើងដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះ បានមកដល់ហើយ។ ឧទាហរណ៍៖ **លោក ក** ដែលជាដើមចោទបានអះអាងអំពីសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាប្រាក់ ទៅតុលាការដោយកាលបរិច្ឆេទនៃការកំណត់សងប្រាក់កម្ចីត្រូវបានមកដល់ ប៉ុន្តែចុងចម្លើយ មិនព្រមបង់ប្រាក់សង ដូចនេះ **លោក ក** អាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចីមកឱ្យខ្លួនបានតាមការសុំរបស់ខ្លួនបាន។

### ៣.២. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត គឺជាបណ្តឹង ដែលដើមចោទ បានដាក់ឡើង ដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់មកដល់នៅឡើយ។ ពាក្យបណ្តឹងនេះ អាចធ្វើឡើងបាន លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុនតែប៉ុណ្ណោះ។ ឧទាហរណ៍៖ **លោក ក** ដែលជាដើមចោទបានអះអាងអំពីសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាប្រាក់ទៅតុលាការ ដោយកាលបរិច្ឆេទនៃការកំណត់សងប្រាក់កម្ចីមិនទាន់ដល់នៅឡើយទេ ប៉ុន្តែ **លោក ក** មានការបារម្ភជាខ្លាំង និង គិតថាចុងចម្លើយអាចនឹងគ្មានលទ្ធភាពសងប្រាក់តាមពេលដែលបានកំណត់ ដោយមូលហេតុចាំបាច់បណ្តាលមកពីចុងចម្លើយកំពុងតែប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ដែលអាចនឹងត្រូវប្រកាសឱ្យក្ស័យធនដោយតុលាការ ដូចនេះ **លោក ក** អាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចី ដែលជាតាវកាលិកនាពេលអនាគត មកឱ្យខ្លួនបានតាមការសុំរបស់ខ្លួនបាន ដោយផ្អែកតាមភាពចាំបាច់ ដែលជាផលប្រយោជន៍ពិសេសនៃបណ្តឹង។

### ៣.៣. សាលក្រមនៃបណ្តឹងនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

ប្រសិនបើតុលាការព្រមទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិ តាមការដែលដើមចោទបានអះអាង នោះតុលាការត្រូវចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកដែលមានខ្លឹមសារកំណត់មួយជាក់លាក់ដូចជាការបង់ប្រាក់ ឬការប្រគល់អចលនវត្ថុជាដើម។ សាលក្រមប្រភេទនេះហៅថា "សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក"ដែលមានអានុភាពកំណត់ជាស្ថាពរអំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ភាគីចំពោះតាវកាលិកនោះ ដែលគេឲ្យឈ្មោះថា "**អាជ្ញាអស់ជំនុំសារធាតុ**"[២៧] ហើយមានអានុភាពអនុវត្តមានន័យថាដើមចោទអាចសម្រេចនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយសាលក្រម តាមការអនុវត្តដោយបង្ខំដោយផ្អែកទៅលើសាលក្រមនោះ ។សាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក គឺជាឧទាហរណ៍ចម្បងមួយនៃលិខិតអនុវត្ត[២៨] ។

ក្នុងករណីដែលតុលាការមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ នោះតុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា "ច្រានចោលការទាមទាររបស់ដើមចោទ" ហើយសាលក្រមប្រភេទនេះក៏មាន "អាជ្ញាអស់ជំនុំសារធាតុ" ផងដែរដែលកំណត់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវការលិកដែលអះអាងដោយដើមចោទ។

---

[២៧] មាត្រា ១៩៤ កថាខណ្ឌទី ២នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៨] មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក និង ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ផ្នែកទី២. បណ្តឹងទាមទារឱ្យបញ្ជាក់

### ៤..អត្ថន័យនៃបណ្តឹងទាមទារឲ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទ នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង។ ក្នុងចំណោមនោះ បណ្តឹងដែលអះអាងនូវអត្ថិភាពនៃសិទ្ធិជាអាទិ៍ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម ហើយបណ្តឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិនោះ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់អសកម្មភាពជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ត្រូវតែជា ការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់ស្តែង។ ឧទាហរណ៍៖ បណ្តឹងទាមទារឱ្យទទួលស្គាល់បុត្តភាព ជាដើម។ល។ការទាមទារនៃបណ្តឹងនេះ ជាបឋម ត្រូវធ្វើការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត និង ជាគោលការណ៍ គឺមិនអនុញ្ញាតឱ្យធ្វើការទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុឡើយ។

### ៤.១. កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបញ្ជាក់

ជាគោលការណ៍ បណ្តឹងទាមទារឲ្យបញ្ជាក់សំដៅតែទៅលើការបញ្ជាក់អំពី “អត្ថភាព” ឬ “នត្ថិភាព”នៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលមានជាក់ស្តែងតែប៉ុណ្ណោះ គឺមិនរាប់បញ្ចូលអំពីការផ្តល់តាវកាលិកណាមួយនោះទេ។ ចំណុចនេះគឺបញ្ជាក់ថា ជាគោលការណ៍ គឺមិនអនុញ្ញាតឲ្យធ្វើការទាមទារបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះទេ។

**ឧទាហរណ៍៖**ប្រសិនបើដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឲ្យ “បញ្ជាក់អំពីអង្គហេតុថាបានសាងសង់A បានសាងសង់អគារ” ឬក៍ “បញ្ជាក់អំពីអង្គហេតុថា B បានធ្វើឲ្យខូចខាតរថយន្តរបស់A” នោះបណ្តឹងទាមទារឲ្យបញ្ជាក់របៀបនេះនឹងត្រូវតុលាការលើកចោល ដោយមូលហេតុខ្វះផលប្រយោជន៍នៃបណ្តឹង[២៩] ពីព្រោះខ្លឹមសារនៃការទាមទាររបស់ដើមចោទ គឺដើម្បីបញ្ជាក់អំពីអង្គហេតុតែប៉ុណ្ណោះ។

បណ្តឹងទាមទារឲ្យបញ្ជាក់ គឺកម្រិតត្រឹមការទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ “នាពេលបច្ចុប្បន្ន” គឺមិនអនុញ្ញាតឲ្យធ្វើក្នុងអតីតកាល ឬអនាគតកាលឡើយ។ទោះបីជាទំនាក់ទំនងគតិយុត្តក្នុងពេលអតីតកាលត្រូវបានបញ្ជាក់ដោយសាលក្រមដែលបានចូល ជាស្ថាពរក៍ដោយ ក៍ស្ថានភាពនៃទំនាក់ទំនងនោះអាចត្រូវបានផ្លាស់ប្តូរនាពេលបច្ចុប្បន្ន។

[២៩] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឬបើទោះបីជា ទំនាក់ទំនងគតិយុត្តនាពេលអនាគត ត្រូវបានបញ្ជាក់ដោយសាលក្រមស្ថាពរក៏ដោយ ក៏ទំនាក់ទំនងនោះអាចនឹងប្រែប្រួល មុនពេលកាលបរិច្ឆេទនាពេលអនាគតនោះមកដល់។ហេតុនេះសាលក្រមនេះ មិនអាចដោះស្រាយវិវាទដែលកំពុងកើតឡើង។

**ឧទាហរណ៍៖** A បានលក់គ្រឿងចក្រទៅឲ្យ B ប៉ុន្តែក្រោយមក A បានលុបចោលកិច្ចសន្យា។ B បានទាមទារ A ឲ្យប្រគល់គ្រឿងចក្រមកឲ្យខ្លួនប៉ុន្តែ A បដិសេធការអនុវត្តកាតព្វកិច្ចប្រគល់គ្រឿងចក្រ ដោយមូលហេតុការលុបចោលកិច្ចសន្យា។ A បានដាក់ពាក្យបណ្តឹងដើម្បីបញ្ជាក់អំពីមោឃភាពនៃកិច្ចសន្យា។

ក៏ប៉ុន្តែបណ្តឹងបែបនេះ គឺពុំបានបង្ហាញអំពីផលប្រយោជន៍នៃបណ្តឹងនោះឡើយ ពីព្រោះបណ្តឹងនេះគឺជាបណ្តឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនាពេលអតីតកាល ដែលមិនអាចដោះស្រាយវិវាទរវាង A និង B ហេតុនេះការទាមទារនឹងត្រូវច្រានចោល។ ប្រសិនបើ A ឈ្នះក្តីនោះសាលក្រមនឹងកំណត់អំពីមោឃភាពនៃកិច្ចសន្យាដែលសាលក្រមនេះអាចនឹងដោះស្រាយវិវាទខាងលើនេះបាន។ក៏ប៉ុន្តែប្រសិន បើA ចាញ់ក្តីវិញ នោះមានន័យថាសេចក្តីសម្រេចក្នុងសាលក្រម នឹងកំណត់អំពីសុពលភាពនៃកិច្ចសន្យាទៅវិញ ប៉ុន្តែពុំបានកំណត់អពីអត្ថិភាពនៃកាតព្វកិច្ចរបស់ A ឡើយ។ ដូច្នេះ ទោះបីជាមានសាលក្រមហើយក៏ដោយ A នៅតែអះអាងថាខ្លួនគ្មានកាតព្វកិច្ចនោះទេ។ A អាចនឹងនិយាយថា យល់ព្រម ខ្ញុំទទួលស្គាល់ថាកិច្ចសន្យានេះមានសុពលភាព ប៉ុន្តែកាតព្វកិច្ចរបស់ខ្ញុំត្រូវបានរលត់ដោយសារតែខ្ញុំបានបំពេញកាតព្វកិច្ចនោះចប់រួចរាល់ ឬបំណុលរបស់ខ្ញុំត្រូវបានលើកលែង ឬក៏ផុតអាជ្ញាយុកាលនៃការរំលត់ទៅហើយ។ Aក៏អាចនឹងធ្វើបណ្តឹងទីពីរទៅតុលាការ ដើម្បីបញ្ជាក់ អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន។

ការផ្តល់ឱកាសលើកទី២ ដល់ Aគឺមិនមានភាពចាំបាច់ និងជាការខាតពេលនៃនីតិវិធីតុលាការ។ដូច្នេះដើម្បីជៀសវៀងនៅបញ្ហានេះ បណ្តឹងលើកទី១ របស់ A គួរតែជាបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច។ ប្រសិនបើ A ធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចគឺអាចទទួលបានដោយសារតែបណ្តឹងបញ្ជាក់ប្រភេទនេះគឺជាបណ្តឹងបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិនាពេលបច្ចុប្បន្ន។

ក៏ប៉ុន្តែមានករណីលើកលែងពិសេសដែលមានការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តក្នុងអតីតកាល និងអនាគតកាលអាចធ្វើទៅបាន ពោលគឺដោយសារភាពចាំបាច់ក្នុងការដោះស្រាយវិវាទ តាមផ្លូវច្បាប់ដែលកំពុងនាពេលបច្ចុប្បន្ននេះ តែប៉ុណ្ណោះ។ថាតើបណ្តឹង ទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដែលមានក្នុងអតីតកាល ឬនាពេលអនាគតកាល អាចទទួលយកបានដែរ ឬអត់នោះ គឺអាស្រ័យលើការអនុវត្តរបស់

ប្រទេសកម្ពុជានាពេលអនាគត។ប៉ុន្តែនេះជាឧទាហរណ៍ អំពីករណីប្រឌិតមួយដែលលើកឡើងអំពី ថាតើបណ្តឹងទាំងនោះមានប្រយោជន៍ក្នុងការដោះស្រាយវិវាទយ៉ាងណាខ្លះ ?

**ឧទាហរណ៍៖**A និង B បានចុះកិច្ចសន្យាមួយ។ យោងតាមកិច្ចសន្យានោះ Aត្រូវទិញទំនិញពីB ជារៀងរាល់ខែ។ Aបានលុបចោលកិច្ចសន្យា ប៉ុន្តែ B បានបន្តផ្ញើវិក័យបត្រជារៀងរាល់ខែ។ប្រសិនបើសុពលភាពនៃកិច្ចសន្យានៅតែមិនច្បាស់លាស់ នោះវិវាទរវាងA និង B នឹងកាន់តែឡើងៗ។ផ្ទុយទៅវិញប្រសិនបើសុពលភាព ឬមោឃភាពនៃកិច្ចត្រូវបានបញ្ជាក់ នោះវិវាទនឹងត្រូវបានដោះស្រាយ (ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ជាក់ថាមានសុពលភាពនោះ A នឹងស្វែងរកមធ្យោបាយដើម្បីរំលាយកិច្ចសន្យា។ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ជាក់ថាមោឃភាពនោះ B នឹងលែងផ្ញើវិក័យបត្រទៀត) ។

បណ្តឹងទាមទារឲ្យបញ្ជាក់ មានគោលបំណងដើម្បីការពារផលប្រយោជន៍របស់ភាគី ក្នុងគោលបំណងដើម្បីដោះស្រាយវិវាទដែលកើតចេញពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ។ ហេតុដូច្នេះបណ្តឹងនេះមិនអនុញ្ញាតឲ្យធ្វើការទាមទារការបញ្ជាក់ការបកស្រាយអំពីសុពលភាព ឬមោឃភាពនៃច្បាប់ណាមួយបានឡើយ។

**ឧទាហរណ៍៖A** បានចំណាយសោហ៊ុយមេធាវីអស់ចំនួន ១០០០ ដុល្លារអាមេរិក ដើម្បីចរចារជាមួយ B ព្រោះ B បានបំពានកិច្ចសន្យាដែលបានធ្វើជាមួយ A ។ A បានគិតថាការខូចខាតដែលមានចែងក្នុងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី គួរតែរាប់បញ្ចូលទាំងសោហ៊ុយមេធាវី។ A ចង់ដាក់ពាក្យបណ្តឹងចំពោះ B ។ក្នុងករណីនេះប្រសិនបើ A ទាមទារឲ្យ ចុងចម្លើយ Bត្រូវបង់ប្រាក់ចំនួន១០០០ ដុល្លារទៅឲ្យដើមចោទ A នោះបណ្តឹងនេះគឺពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ជាក់ស្តែងមួយ។ផ្ទុយទៅវិញប្រសិនបើ A ទាមទារឲ្យ បញ្ជាក់ការខូចខាតដែលមានចែងក្នុងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី រាប់បញ្ចូលទាំងសោហ៊ុយមេធាវី នោះបណ្តឹងនេះមិនពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ជាក់ស្តែងនោះទេ ហេតុដូច្នេះការទាមទារនឹងត្រូវតុលាការច្រានចោល។

### ៤.២. សាលក្រមនៃបណ្តឹងទាមទារឲ្យបញ្ជាក់

គោលបំណងនៃបណ្តឹងទាមទារឲ្យបញ្ជាក់ គឺជាការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយដែលអះអាងដោយដើមចោទ។ហេតុដូច្នេះតុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃ ឬទំនាក់ទំនងគតិយុត្ត ដែលសាលក្រមដែលទទួលស្គាល់អំពីភាពត្រឹមត្រូវនៃការទាមទារ ឈ្មោះថា **សាលក្រមបញ្ជាក់ ។**

សាលក្រមបញ្ជាក់មានអានុភាពទៅលើការវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តណាមួយដែលមាននៅក្នុងខ្លឹមសារនៃសាលក្រមនោះ។សិទ្ធិជាក់លាក់នេះមិនអាចយកមកវិនិច្ឆ័យម្តងទៀតបានឡើយពីព្រោះវាជាអាជ្ញាអស់ជំនុំជាសារធាតុ ហើយមានអានុភាពជាស្ថាពរ។ ចំពោះសាលក្រមដែលធ្វើការច្រានចោលការទាមទារឲ្យបញ្ជាក់ ក៏មានអានុភាពជាអាជ្ញាអស់ជំនុំជាសារធាតុផងដែរ។ម្យ៉ាងវិញទៀត ក្នុងករណីដែលអត្ថិភាព ឬនត្ថិភាពនៃកាតព្វកិច្ចជាចំណុចវិវាទ មានបណ្តឹងទាមទារឲ្យបញ្ជាក់អសកម្មមួយប្រភេទដែលត្រូវបានចង្អុលថាកូនបំណុលដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចក្នុងនាមជាដើមចោទ។សាលក្រមច្រានចោលនូវការទាមទារក្នុងបណ្តឹងទាមទារឲ្យបញ្ជាក់នេះ នឹងមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុ ចំពោះការវិច្ឆ័យថា "កាតព្វកិច្ចដែលដើមចោទបានអះអាងថាពុំមា ននោះ មានអត្ថិភាព"។ចំពោះចុងចម្លើយ សាលក្រមនេះគឺជាសាលក្រមបញ្ជាក់ជាស្ថាពរនូវអត្ថិភាពនៃសិទ្ធិលើបំណុល ក៏ប៉ុន្តែ នេះក៏សាលក្រមបញ្ជាក់ ហើយពុំមានអានុភាពអនុវត្តទេ ហេតុនេះហើយ មិនអាចក្លាយទៅជាលិខិតអនុវត្ត[៣០] ដើម្បីសម្រេចសិទ្ធិលើបំណុលដដែលត្រូវបានទទួលស្គាល់ក្នុងសាលក្រមនោះឡើយ។

## ផ្នែកទី៣. បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

### ៥.. អត្ថន័យនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត( ការបង្កើត ការប្តូរ ឬ ការរំលត់ ) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង។ ឧទាហរណ៍ដូចជាៈ បណ្តឹងលែងលះ ដែលជាបណ្តឹងទាមទារឱ្យរំលត់នូវទំនាក់ទំនងរវាងសហព័ទ្ធ ហើយក៏ជាបណ្តឹងទាមទារឱ្យបង្កើតនូវទំនាក់ទំនងគតិយុត្តផងដែរ ពោលគឺសម្តៅទៅលើការបែងចែកទ្រព្យសម្បត្តិ និង ការកំណត់អំណាចមេបាលើកូន( ប្រសិនបើមាន )ជាដើម។ បណ្តឹងសុំរំលាយកិច្ចសន្យា គឺជាបណ្តឹងទាមទារឱ្យរំលត់នូវទំនាក់ទំនងគតិយុត្ត ឬ កាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា។

### ៥.១. កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តត្រូវមានការអះអាងអំពីអត្ថិភាពនៃសិទ្ធិតាមទំនាក់ទំនង ឬត្រូវមានការអះអាងអំពីអត្ថិភាពនៃមូលហេតុ ក្នុងការបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដូចជាមូលហេតុនៃការសុំជំនុំជម្រះសាជាថ្មីទៅលើសាលក្រមស្ថាពរ ជាដើម។

[៣០] មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក

ទោះជាបណ្តឹងដែលមានគោលបំណងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដូចគ្នាក៏ដោយ តែមិនបានអះអាងអំពីសិទ្ធិ និងមូលហេតុនៃការបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តនោះទេហើយតុលាការក៏គ្មានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយដើម្បីយកមកបង្កើត ទំនាក់ទំនងគតិយុត្តនោះទេ។

ដូច្នេះ បណ្តឹងបែបនេះមិនចាត់ចូលជាបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដូចដែលបានរៀបរាប់មកពីខាងដើមនោះទេ។បណ្តឹងបែបនេះ គេហៅថា “ **បណ្តឹងទាមទារឲ្យបង្កើត ប្តូរ រំលត់ទំនាក់ទំនងគតិយុត្តតាមទម្រង់” ។ឧទាហរណ៍** ៖ បណ្តឹងឲ្យបែងចែកវត្ថុដែលជាកម្មសិទ្ធិអវិភាគ [៣១]។

បណ្តឹងប្រភេទនេះ ទោះជាមានការបង្ហាញឆន្ទៈពីភាគីក៏ដោយ ក៏គ្មានអានុភាពអនុវត្តដែរ ប្រសិនបើមិនបានឆ្លងកាត់តាមការធ្វើសេចក្តីសម្រេចដោយសាលក្រមរបស់តុលាការទេនោះ។

## ៥.២. សាលក្រមចំពោះបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

ប្រសិនបើតុលាការទទួលស្គាល់តាមការអះអាងរបស់ដើមចោទចំពោះការទាមទារ នោះតុលាការត្រូវចេញសាលក្រមកំណត់នូវទំនាក់ទំនងគតិយុត្តមួយយ៉ាងជាក់លាក់។សាលក្រមប្រភេទនេះហៅថា “**សាលក្រមបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**” ។សាលក្រមខាងលើនេះ មានអានុភាពប្រតិសកម្ម( ឧទាហរណ៍ សាលក្រមរំលាយចោលនូវសេចក្តីសម្រេចរបស់មហាសន្និបាទម្ចាស់ហ៊ុនជាដើម មានន័យថា បើតុលាការទទួលស្គាល់ការរំលាយចោលនូវសេចក្តីសម្រេចរបស់មហាស្និបាទម្ចាស់ហ៊ុន នោះសាលក្រមមានអានុភាពប្រតិសកម្មទៅចាប់ពីពេលដែលសាលក្រមបានចូលជាស្ថាពរ ដោយអ្វីៗដែលបានធ្វើពីមុនរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកថានិរាករណ៍) ឬមានអានុភាពឆ្ពោះទៅអនាគត (ឧទាហរណ៍សាលក្រមលែងលះ)។អានុភាពទាំងនេះ វាអាស្រ័យទៅនឹងការកំណត់ដោយច្បាប់សារធាតុ ឬតាមច្បាប់នីតិវិធីស្រមតាមខ្លឹមសារនៃសាលក្រម។

សាលក្រមបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត នឹងបង្កើតជាអាជ្ញាអស់ជំនុំសារធាតុចំពោះការវិនិច្ឆ័យថា មានសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ឬមានមូលហេតុបង្កើតទំនាក់ទំនងគតិយុត្តដែលដើមចោទបានអះអាង។ម្យ៉ាងទៀត ក្នុងករណីដែលតុលាការមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទ នោះតុលាការត្រូវចេញសាលក្រមច្រានចោល។ សាលក្រមច្រានចោលនេះ មិនមានអានុភាពបង្កើតទំនាក់ទំនងគតិយុត្តទេ ប៉ុន្តែចំណុចវិនិច្ឆ័យអំពី “ពុំមានបង្កើត ឬពុំមានមូលហេតនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះ វាមានអានុភាពអាជ្ញាអស់ជំនុំសារធាតុរវាងភាគី ដែលលក្ខណៈរបៀបនេះហៅថា **សាលក្រមបញ្ជាក់ ។**

[៣១] មាត្រា ២១១ ក្រមរដ្ឋប្បវេណី

ជារួមមក ផលប្រយោជន៍នៃការធ្វើបណ្តឹងចំពោះការទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តអាចទទួលស្គាល់បាន លុះត្រាតែអត្ថិភាពនៃសិទ្ធិ និងអត្ថិភាពនៃមូលហេតុនោះ មានចែងក្នុងលក្ខខណ្ឌដែលមានកំណត់ក្នុងច្បាប់។

# ជំពូកទី៣

# អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬអង្គហេតុចម្បង

អង្គហេតុចម្បងគឺជា អង្គហេតុដែលកើតឡើងនូវទំនាក់ទំនងគតិយុត្តពិសេសណាមួយ ហើយយើងអាចបែងចែកអង្គហេតុចម្បងជា៤ប្រភេទគឺ (១)**អង្គហេតុកើតឡើងនៃសិទ្ធិ** (២)**អង្គហេតុរារាំងសិទ្ធិ** (៣)**អង្គហេតុរលត់សិទ្ធិ** និង(៤)**អង្គហេតុទប់ស្កាត់(បដិសេធ)សិទ្ធិ។ អង្គហេតុដែលកើតឡើងនូវសិទ្ធិ**គឺជាអង្គហេតុដែលជាមូលហេតុនៃការកើតឡើងសិទ្ធិ អង្គហេតុរាំងសិទ្ធិ គឺជាអង្គដែលជាមូលហេតុនៃការរលត់សិទ្ធិ គឺជាករណី ដែលសិទ្ធិនោះកើតឡើងហើយប៉ុន្តែរលត់ទៅវិញ ចំណែកឯអង្គហេតុដែលទប់ស្កាត់ គឺជាករណីសិទ្ធិនោះកើតឡើង ប៉ុន្តែមិនអាច ប្រើប្រាស់បានទេ។

**ឧទាហរណ៍៖ ទាក់ទងនឹងអង្គហេតុទាំង៤ដូចខាងក្រោម៖**

X ទាមទារឲ្យ Y បង់តម្លៃនៃនាឡិកា ដោយមូលហេតុថា X និង Y ធ្វើកិច្ចសន្យាលក់-ទិញនាឡិកា។ដើម្បីគាំទ្រការទាមទារ X ត្រូវការអះអាងអំពីកិច្ចសន្យាលក់-ទិញនៃនាឡិកា ហើយអង្គហេតុបែបនេះ គឺជា **អង្គហេតុដែលជាមូលហេតុនៃការកកើតឡើងនូវសិទ្ធិ** ប៉ុន្តែ ប្រសិនបើមានមូលហេតុនៃមោឃភាពនៅក្នុងកិច្ចសន្យានេះ អានុភាពនៃកិច្ចសន្យាមិនកើតឡើងទេ អង្គហេតុបែបនេះ ជា**អង្គហេតុរារាំងការកើតឡើងសិទ្ធិ** ។ ទោះបីជាកិច្ចសន្យាលក់-ទិញនាឡិកា ត្រូវធ្វើឡើងក៏ដោយ ប្រសិនបើមានវិការៈក្នុងការបង្ហាញឆន្ទៈ កិច្ចសន្យានេះត្រូវបានលុបចោល ហើយអានុភាពនៃការលុបចោលកិច្ចសន្យា ក្លាយជាមោឃៈតាំងពីដំបូង ដូចនេះអង្គហេតុនៃការលុបចោលកិច្ចសន្យា គឺជា **អង្គហេតុរលត់សិទ្ធិ** ប៉ុន្តែ ទោះបីជាកិច្ចសន្យានោះ មានសុពលភាពក៏ដោយ ប្រសិនបើ X ទាមទារឲ្យ Y បង់តម្លៃ ដោយគ្មានការប្រគល់នាឡិកាទេ Y អាចបដិសេធមិនបង់តម្លៃបាន ដោយអះអាងអំពីសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា នេះជាឧទាហរណ៍នៃ **អង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ។**

## ផ្នែកទី១. ទ្រឹស្តី និងការបែងចែកអង្គហេតុ

គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី គឺរក្សាការពារសិទ្ធិដែលត្រូវបានចែងដោយច្បាប់សារធាតុ ដូចនេះកម្មវត្ថុនៃការវិនិច្ឆ័យក្នុងនីតិវិធីបណ្តឹងគឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលស្ថិតនៅក្រោមច្បាប់សារធាតុ។នៅក្នុងបណ្តឹងរដ្ឋប្បវេណី តុលាការត្រូវសម្រេចថាតើបណ្តឹងទាមទារនោះ មានឬ គ្មានមូលហេតុត្រឹមត្រូវ មានន័យថាដើមចោទមាន ឬគ្មានសិទ្ធិ ហើយសិទ្ធិទាមទាររបស់ដើមចោទ គឺជាចំណុចដែលតុលាការមិនអាចយល់ដឹងផ្ទាល់បានទេ ពីព្រោះសិទ្ធិគឺជាទស្សនវិស័យអរូបីយ ដែលមិនអាចប៉ះ ឬមើលឃើញបាន។

ដូច្នេះ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ តុលាការត្រូវវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលកើតឡើងសិទ្ធិនោះ ពីព្រោះអង្គហេតុ គឺជាចំណុចដែលអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពបានដោយភស្តុតាង។ **ឧទាហរណ៍៖** X ដាក់ពាក្យបណ្តឹងទាមទារឲ្យ Y បញ្ជាក់កម្មសិទ្ធិនៃនាឡិកាដែលគាត់កាន់កាប់ ទោះបី X ដាក់ពាក្យបណ្តឹងតាមទារឲ្យបញ្ជាក់នូវកម្មសិទ្ធិនោះ ក៏កម្មសិទ្ធិជាទស្សនអរូបី មិនអាចប៉ះ ឬមើលបានទេ ដោយឡែក។

នាឡិកាជាវត្ថុ ដូចនេះ អាចប៉ះ ឬមើលបាន ប៉ុន្តែកម្មសិទ្ធិនៃនាឡិកាជាទស្សនវិស័យអរូបី មិនអាចយល់ដឹងថា អ្នកណាជាកម្មសិទ្ធិករឡើយ ទោះបីជាអាចប៉ះ ឬមើលបានក៏ដោយ។ដូចនេះ ដើម្បីបញ្ជាក់កម្មសិទ្ធិ តុលាការតម្រូវឲ្យកម្មសិទ្ធិករអះអាងនូវអង្គហេតុដែលកើតឡើងនូវសិទ្ធិនោះ ដូចជា ប្រសិនបើ X បានទិញនាឡិកានោះនៅផ្សារ តុលាការឲ្យដើមចោទនោះអះអាងថាទិញពីពេលណា? ពីអ្នកណា?តម្លៃប៉ុន្មាន? និងឲ្យដើមចោទដាក់ភស្តុតាងដូចជា កិច្ចសន្យាលក់ទិញ ឬ វិក័យបត្រ ជាអាទិ៍ ហើយតាមរយៈភស្តុតាងនេះ តុលាការអាចយល់ដឹងអំពីកិច្ចសន្យាលក់ទិញ និងដឹងថា អ្នកណាជាកម្មសិទ្ធិករនៃនាឡិកានោះ។អង្គហេតុ ដូចជាកិច្ចសន្យាលក់ទិញនេះ គឺជាអង្គហេតុដែលជាមូលហេតុនៃការបង្កើតទំនាក់ទំនងតាមផ្លូវច្បាប់ ដែលយើងហៅថា "**អង្គហេតុចម្បង** " ។

## ៦.តួនាទីនៃអង្គហេតុចម្បងក្នុងសកម្មភាពបណ្តឹងជាក់ស្តែង

សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងជាចំណុចដែល មិនអាចយល់ដឹងដោយផ្ទាល់ទេ ដូចនេះ ភាគីត្រូវអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ មូលហេតុ នៃការតវ៉ា ប្រសិនបើ ភាគីមិនអះអាងអង្គហេតុទេ តុលាការ មិនអាចយកអង្គហេតុនោះ មកធ្វើជាមូលដ្ឋាននៃ សាលក្រមបានឡើយ[៣២]( មាតា៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូចនេះ៖ ភាគីត្រូវអះអាងអង្គហេតុទាំងនោះ ក្នុងបណ្តឹង និងត្រូវធ្វើការបញ្ជាក់ ក្នុងន័យនេះ អង្គហេតុចម្បង ក្លាយជាកម្មវត្ថុនៃសកម្មភាពបណ្តឹងរបស់ភាគី ។

ទាក់ទងនឹងអង្គហេតុនេះ មានលំដាប់តាមទ្រឹស្តីហៅថា អង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុតវ៉ា អង្គហេតុតវ៉ាតប ហើយទាក់ទងចំណុចនេះ នឹងពន្យល់ជូនដោយលើកឧទាហរណ៍ជាក់ស្តែង ដូចខាងក្រោម៖**ឧទារហណ៍** _X ទាមទារតម្លៃផ្អែកលើកិច្ចសន្យាលក់-ទិញនាឡិកា ករណីនេះ កម្មវត្ថុនៃបណ្តឹង គឺ សិទ្ធិទាមទារតម្លៃផ្អែកលើកិច្ចសន្យាលក់-ទិញ ហើយអង្គហេតុដែលជាមូលេហាតុនៃការទាមទារ គឺការកើត ឡើងនៃកិច្ចសន្យាលក់-ទិញតែប៉ុណ្ណោះ ។

[៣២] មាតា៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ទាក់ទងនឹងកិច្ចសន្យាលក់-ទិញ អាចបង្កើតឡើងដោយការព្រមព្រៀង របស់ភាគីតែប៉ុណ្ណោះ ដូចនេះ៖ ដើមចោទមិនចាំបាច់អះអាងថា កិច្ចសន្យាលក់-ទិញ ត្រូវធ្វើឡើងជាលាយ លក្ខណ៍អក្សរនោះទេ ហើយដើម្បីធ្វើកិច្ចសន្យាលក់-ទិញ អ្នកលក់មិនចាំបាច់បញ្ជាក់ថា ខ្លួនជាកម្មសិទ្ធិករនៃ វត្ថុ និងមិនចាំបាច់អះអាងអំពីពេលកំណត់បង់តម្លៃនោះទេ ពីព្រោះអ្នកទិញ មានករណីកិច្ចបង់តម្លៃពេលអ្នកលក់ ទាមទារដូចនេះ៖ ការយល់ដឹងអំពីអង្គហេតុចម្បងដោយត្រឹមត្រូវ ជាចំណុចសំខាន់ណាស់ ដើម្បីធ្វើសកម្មភាពបណ្តឹង ដោយមានប្រសិទ្ធភាព។

ក្នុងករណី_X អះអាងអង្គហេតុ ដែលជាមូលហេតុនៃការទាមទារបែបនេះ Y អាចអះអាងអង្គហេតុតវ៉ា ដើម្បីបដិសេធ ការទាមទាររបស់ X ដូចជា នាឡិកានោះ គឺជារបស់ក្លែងក្លាយនៃម៉ាក្រឡុក ហើយពេលទិញនាឡិកាខ្លួនគិតថា នាឡិកានោះជា ម៉ាករូឡិកពិតមែន ក្នុងករណីនេះ ដើម្បីបដិសេធការទាមទាររបស់ X Y ត្រូវអះអាងអង្គហេតុតវ៉ាក្នុងបណ្តឹង ។

អង្គហេតុតវ៉ា គឺជាអង្គហាតុស្របទៅតាមអង្គហេតុ ដែលជាមូលហេតុនៃ ការទាមទាររបស់ដើមចោទ ហើយអ្នកដែលអះអាងអង្គហេតុតវ៉ា ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ ឧទាហរណ៍Y អាចអះអាងថា លុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ ហើយអះអាងថា សិទ្ធិទាមទារតម្លៃត្រូវរលត់ដោយការលុបចោល (មាត្រា៣៤៦នៃក្រមរដ្ឋប្បវេណី ឬ Y អាចអះអាងថា ដោយសារ X មិនទាន់ប្រគល់នាឡិកាទេ ដូចនេះ Y_មិនបង់លុយ រហូតដល់ X ប្រគល់នាឡិកាដល់Y សិទ្ធិតវ៉ានេះ ត្រូវបានហៅថា សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា (មាត្រា៥៥៨នៃក្រម រដ្ឋប្បវេណី) ។ ដូចនេះ អង្គហេតុចម្បង គឺជាចំណុចសំខាន់ៗ ដើម្បីយល់ដឹងថា ភាគីត្រូវ អះអាងចំណុចអ្វីនៅក្នុងបណ្តឹងជាក់ស្តែង ។

គំនិតស្រដៀងគ្នានឹងអង្គហេតុតវ៉ា គឺការមិនទទួលស្គាល់ ។ អង្គហេតុតវ៉ាជាអង្គហេតុដែលស្របតាមអង្គហេតុដែលជាមូលហេនៃការទាមទារ ហើយជាអង្គហេតុដែលចុងចម្លើយទទួលខុសត្រូវក្នុងការបញ្ជាក់។ **ឧទាហរណ៍** ៖ ជាក់ស្តែងនៃអង្គហេតុតវ៉ា ដើមចោទ ទាមទារប្រាក់កម្ចីចុងចម្លើយ អះអាងថា លុយទេ វិញហើយនេះគឺជាអង្គហេតុតវ៉ា។ ពីព្រោះការសង គឺជាអង្គហេតុស្របទៅតាមអង្គហេតុដែលជាមូលហេតុ ។ ទាមទារឱ្យសងប្រាក់កម្ចី ដែលកិច្ចសន្យាខ្ចីបរិភោគកើតឡើងដោយ (១) ការព្រមព្រៀង (២) ការប្រគល់ប្រាក់ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ និង(៣) ការមកដល់នូវពេលកំណត់សង ហើយការសង គឺជា អង្គហេតុដែល នឹងការរលត់នៃសិទ្ធិផ្អែកលើកិច្ចសន្យាខ្ចីបរិភោគនេះ ហើយចុងចម្លើយ នឹងទទួលខុសត្រូវក្នុងការបញ្ជាក់អង នៃការសង។ រីឯឧទាហរណ៍នៃការមិនទទួលស្គាល់គឺ ចុងចម្លើយបដិសេធអង្គហេតុ ប្រគល់លុយ ។ ការប្រគល់ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ជាអង្គហេតុដែលដើមចោទ ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ ហើយករណី ចុងចម្លើយ

អះអាងថា ខ្ញុំមិនទទួលលុយទេ ដោយសារថ្ងៃដែលដើមចោទអះអាងថា គាត់ប្រគល់លុយ ខ្ញុំទៅបរទេស ករណីបែបនេះយើង ហៅថា មិនទទួលស្គាល់អង្គហេតុដោយភ្ជាប់ជាមួយមូលហេតុ ប៉ុន្តែមូលហេតុនៃមិនទទួល ស្គាល់មិនមែនជាអង្គហេតុចម្បងទេ ដូចនេះ៖ ចុងចម្លើយ មិនទទួលខុសត្រូវ ក្នុងការបញ្ជាក់មូលហេតុនោះទេ។

### ៦.១. អង្គហេតុដែលនាំអោយមានការកើតឡើងនូវសិទ្ធ

អង្គហេតុនៃការកកើតឡើងនូវសិទ្ធិ គឺសំដៅលើអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនូវសិទ្ធិរវាងទំនាក់ទំនងបុគ្គលនៅក្នុងព្រឹត្តិការណ៍ ឬសកម្មភាពណាមួយ។

ឧទាហរណ៍៖ **ក** ទាមទារឲ្យ **ខ** បង់តម្លៃនៃម៉ូតូដោយមូលហេតុ **ក** និង **ខ** បានបង្កើតកិច្ចសន្យាទិញលក់ ម៉ូតូជាមួយគ្នា(យោងតាមមាត្រា ៥១៥ និងមាត្រា ៥៥៥នៃក្រមរដ្ឋប្បវេណី)។

### ៦.២. អង្គហេតុនៃការរារាំងការកកើតសិទ្ធិ

អង្គហេតុនៃការរារាំងការកកើតសិទ្ធិមានន័យថា រារាំងសិទ្ធិមិនឲ្យកើតមានអត់មានសិទ្ធិទាមទារ។អង្គហេតុផ្សេងបានរារាំងអានុភាពនៃកិច្ចសន្យា (ឧទាហរណ៍ ៖កិច្ចសន្យាផ្ទុយសណ្តាប់ធ្នាប់សាធារណៈ យោងតាមមាត្រា ៣៥៤......ទោះបីកិច្ចសន្យាមានក័ដោយ ក៏ប៉ុន្តែមានអង្គហេតុផ្សេងរារាំងអានុភាពនៃកិច្ចសន្យានោះ)។

### ៦.៣. អង្គហេតុនៃការរំលត់សិទ្ធិ

អង្គហេតុនៃការរលត់សិទ្ធិ គឺសិទ្ធិកើតមានហើយ តែសិទ្ធិនោះត្រូវបានរលត់ទៅវិញ (ឧទាហរណ៍ៈ ដោយការសង យោងតាមមាត្រា៤៣៣ នៃក្រមរដ្ឋប្បវេណី)។

### ៦.៤.អង្គហេតុនៃការទប់ស្កាត់ការប្រើប្រាស់សិទ្ធិ

អង្គហេតុនៃការទប់ស្កាត់ការប្រើប្រាស់សិទ្ធិ សិទ្ធិកើតមានហើយ គឺមិនទាន់អាចអនុវត្តសិទ្ធិនោះបានដោយអង្គហេតុផ្សេងៗ (ឧទាហរណ៍ៈ សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា[៣៣] ដែលមានចែងក្នុងមាត្រា ៥៥១ និងមាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណី...ទោះម្ចាស់បំណុលមានសិទ្ធិហើយក៏ដោយ តែកូនបំណុលអាចបដិសេធសិទ្ធិនោះបាន)។

### ផ្នែកទី២. លំហូរនៃការបញ្ជាក់អង្គហេតុ

ដើម្បីអាចឲ្យតុលាការសម្រេចសេចក្តីទៅតាមការទាមទាររបស់ខ្លួន ភាគីនីមួយៗត្រូវធ្វើនូវសកម្មភាពមួយចំនួននៅក្នុងនីតិវិធីនៃបណ្តឹងរបស់ខ្លួន ដោយហេតុថា តុលាការនៃរឿងក្តីរដ្ឋប្បវេណីគឺជាតុលាការអកម្ម។

[៣៣] ក្រមរដ្ឋប្បវេណី មាត្រា ៥៥១ និងមាត្រា ៥៥៨

មានន័យថា តុលាការមិនអាចយកអង្គហេតុណាដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ [៣៤]។ម៉្យាងវិញទៀតតុលាការមិនអាចដឹងថា តើអង្គហេតុណាមួយជាអង្គហេតុពិតប្រាកដ ឬជាអង្គហេតុក្លែងក្លាយនោះទេ លុះត្រាតែគូភាគីលើកយកនូវភស្តុតាងការបញ្ជាក់ឲ្យកាន់តែច្បាស់លាស់អំពីទំនាក់ទនងរវាងភស្តុតាងទៅនឹងសិទ្ធិ និងផលប្រយោជន៍ចំពោះការទាមទាររបស់ខ្លួន។ជាទូទៅតុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ប៉ុន្តែតុលាការអាចពិចារណាអំពីស្ថានភាពទាំងមូលដែលបានលើកឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន។

អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការអាចទទួលស្គាល់អង្គហេតុនោះបានដោយពុំចាំបាច់ផ្អែកលើភស្តុតាងនោះទេ [៣៥]។

## ៧. ការទាមទារ

គោលគំនិតនៃការទាមទារ គឺជាផ្នែកសន្និដ្ឋាននៃការអះអាងរបស់ដើមចោទនៅក្នុងបណ្តឹង(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ខ)។ នៅក្នុងដំណាក់កាលដំបូងនៅក្នុងនីតិវិធីដែលភាគីត្រូវធ្វើ គឺការទាមទារ ដែលភាគីត្រូវធ្វើការអះអាងអំពីអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុដែលបានកំណត់។ក្នុងការសរសេរពាក្យបណ្តឹងទាមទារទៅតុលាការ ភាគីត្រូវសរសេរចំណុចទាំងឡាយដែលខ្លួនចង់ទាមទារ ដើម្បីឲ្យតុលាការចេញសេចក្តីសម្រេចតាមការទាមទាររបស់ខ្លួន ដោយហេតុថា តុលាការអាចចេញសេចក្តីសម្រេចបាន លុះត្រាតែមានបណ្តឹងទាមទារពីគូភាគី។ ផ្ទុយទៅវិញ ប្រសិនបើភាគីមិនបានបញ្ជាក់ការទាមទារនៅក្នុងពាក្យបណ្តឹងរបស់ខ្លួនទេ បណ្តឹងនោះនឹងមានលក្ខណៈមិនគ្រប់គ្រាន់ដែលគ្មានផលប្រយោជន៍នៃបណ្តឹង ហើយជាហេតុនាំឲ្យតុលាការលើកបណ្តឹងចោលដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន។ហេតុនេះហើយ ការទាមទារគឺជាចំនុចដ៏សំខាន់ដែលភាគីចាំបាច់ត្រូវធ្វើការបញ្ជាក់នៅក្នុងបណ្តឹង។

### ៧.១. កម្មវត្ថុនៃបណ្តឹង

កម្មវត្ថុនៃបណ្តឹងគឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹង(ការអះអាងរបស់ដើមចោទ)។

ឧទាហរណ៍៖ សិទ្ធិទាមទារឲ្យបង់ថ្លៃលក់ទិញ ដោយផ្អែកលើកិច្ចសន្យាលក់ទិញមួយ។

ជាទូទៅ បណ្តឹងរដ្ឋប្បវេណីមានគោលបំណងដោះស្រាយនូវវាល់វិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ទាក់ទង

[៣៤] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៥

ទៅនឹងសិទ្ធិរបស់បុគ្គលឯកជន។ហេតុដូចនេះ វិវាទទាំងឡាយណាដែលមិនមែនជាកម្មវត្ថុនៃវិវាទតាមផ្លូវឯកជន ជាក់ស្តែងនោះទេ តុលាការពុំអាចដោះស្រាយដោយសាលក្រមបានឡើយ ដូចជាវិវាទទាក់ទងនឹងការបកស្រាយទ្រឹស្តី ឬច្បាប់ណាមួយ ជាអាទិ៍។

### ៧.២. មូលហេតុនៃការទាមទារ

គ្រប់ការទាមទារទាំងអស់ សុទ្ធតែមានមូលហេតុគតិយុត្តដែលផ្សាភ្ជាប់គ្នារវាងសិទ្ធិនិងកាតព្វកិច្ច។ ឧទាហរណ៍៖ ករណីកិច្ចរបស់ភាគីអ្នកលក់ និងភាគីអ្នកទិញ ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី" អ្នកមានករណីកិច្ចផ្ទេរកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់" ។

ករណីនេះប្រសិនបើភាគីអ្នកលក់បានផ្ទេរកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតដែលមានលើវត្ថុហើយនោះ ភាគីអ្នកទិញត្រូវប្រគល់ប្រាក់ដែលជាតម្លៃតបមកឲ្យភាគីអ្នកលក់វិញ ផ្ទុយទៅវិញ ប្រសិនបើភាគីអ្នកទិញមិនបានប្រគល់ប្រាក់មកឲ្យភាគីអ្នកលក់ទេនោះ ភាគីអ្នកលក់មានសិទ្ធិទាមទារឲ្យបង់តម្លៃតបនៃវត្ថុបានដោយផ្អែកលើសិទ្ធិលើបំណុលដោយផ្អែកលើកិច្ចសន្យាលក់ទិញនោះ ករណីនេះអនុវត្តដូចគ្នាផងដែរប្រសិនបើភាគីអ្នកលក់មិនអនុវត្តករណីកិច្ចរបស់ខ្លួន។ក្នុងករណីដែលដើមចោទធ្វើការទាមទារ ហើយចុងចម្លើយទទួលស្គាល់ការទាមទារនោះ តុលាការនឹងកត់ត្រានៅក្នុងកំណត់ហេតុស្តីពីការសះជាកំណត់ហេតុស្តីពីការសះជាកំណត់ហេតុស្តីពីការសះជានេះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរ [៣៦]។

កំណត់ហេតុស្តីពីការសះជា សំដៅលើលិខិតដែលកត់ត្រាអំពីលទ្ធផលនៃការផ្សះផ្សាដែលភាគីបានយល់ព្រមព្រៀងគ្នា និងនាំឲ្យរឿងក្តីត្រូវបានបញ្ចប់ ហើយវាមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ។ ករណីដែលដើមចោទទាមទារ ហើយចុងចម្លើយមិនទទួលស្គាល់ការទាមទារនោះតុលាការនឹងឲ្យដើមចោទធ្វើការអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ បន្ទាប់មកភាគីទាំងសងខាងត្រូវទទួលបន្ទុកក្នុងការស្វែងរកភស្តុតាងដើម្បីបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទនងគតិយុត្តផ្សេងទៀតចំពោះអង្គហេតុដែលបានលើកឡើង។ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុរបស់ចុងចម្លើយ អាចធ្វើឡើងបានតាម ៤របៀប៖

ការទទួលស្គាល់នូវការទាមទារ គឺជាការបង្ហាញឆន្ទៈទទួលស្គាល់ទាំងស្រុងនូវការទាមទារតាមផ្លូវបណ្តឹងដោយចុងចម្លើយ។ តាមរយៈការទទួលស្គាល់នេះ បណ្តឹងអាចត្រូវបានបញ្ចប់ហើយត្រូវសរសេរក្នុងកំនត់ហេតុថា បានទទួលស្គាល់នូវការទាមទារ ហើយកំណត់ហេតុនេះមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។

[៣៦] មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ៧.៣.ការអះអាង

ការអះអាងរបស់ភាគី គឺជាសកម្មភាពបង្ហាញចំពោះតុលាការនូវអង្គហេតុដែលជាមូលដ្ឋាននៃអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលទាមទារតាមផ្លូវបណ្តឹង។ជាគោលការណ៍ការអះអាងរបស់ភាគី គេមិនចាត់ទុកថាជា ភស្តុតាងនោះទេ។ការអះអាងរបស់ភាគីចុងចម្លើយ គឺជាការលើកឡើងនូវបញ្ហាតាមផ្លូវច្បាប់បញ្ជាក់

អំពីនត្ថិភាពនៃសិទ្ធិ។ដូចនេះ ដើម្បីប្រឆាំងតបនឹងដើមចោទ ចុងចម្លើយអាចមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬក៏អាចអះអាងតវ៉ាចំពោះដើមចោទបាន។ចំណែកឯការអះអាងរបស់ភាគីដើមចោទវិញ គឺជាការលើកឡើងនូវបញ្ហាតាមផ្លូវច្បាប់ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ។

## ៧.៤.មូលហេតុដែលអនុញ្ញាតឲ្យធ្វើការអះអាង

មុននឹងឈានដល់ការសម្រេចសេចក្តីតុលាការ ត្រូវពិចារណាទៅលើអង្គហេតុដែលគូភាគីបានលើកឡើង តាមរយៈការបង្ហាញភស្តុតាងជាមួយនឹងការអះអាងដែលគូភាគីត្រូវធ្វើការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តនៃសិទ្ធិ។តុលាការអាចសម្រេចទៅលើចំណុចណាដែលគូភាគីបានទាមទារប៉ុណ្ណោះ ម្យ៉ាងវិញទៀត បើទោះបីជាមានអង្គហេតុជាក់ស្តែងដែលមានផលប្រយោជន៍សម្រាប់ភាគីក៏ដោយ តែបើភាគីមិនបានអះអាងទេ តុលាការមិនអាចពិនិត្យនូវអង្គហេតុនោះដើម្បីចេញសាលក្រមបានឡើយ។ ការណ៍នេះហើយធ្វើឲ្យភាគីរងនូវការខូចប្រយោជន៍ដោយសារតែតុលាការមិនអាចទទួលស្គាល់នូវអានុភាពគតិយុត្ត ដែលមានប្រយោជន៍សម្រាប់ភាគីនោះ( ដូចជាការកកើត ឬ ការរលត់នូវសិទ្ធិជាអាទិ៍ )។ ដោយហេតុនេះហើយ ភាគីត្រូវទទួលខុសត្រូវធ្វើការអះអាងនូវអង្គហេតុដែលមានប្រយោជន៍ដល់ ខ្លួន ប្រសិនខ្លួនចង់ឈ្នះក្តី ហើយការទទួលខុសត្រូវនេះគេហៅថា" **ការទទួលខុសត្រូវក្នុងការអះអាង** " ។

**ឧទាហរណ៍៖** បើទោះបីជាមានអង្គហេតុថា ចុងចម្លើយបានសងប្រាក់កម្ចីនោះរួចហើយក៏ដោយ តែបើចុងចម្លើយមិនបានអះអាងទេ តុលាការមិនអាចយកអង្គហេតុនោះមកពិចារណាបានឡើយ ដោយហេតុនេះតុលាការទទួលស្គាល់ថា កាតព្វកិច្ចរបស់ចុងចម្លើយបានរលត់ដោយការសងនោះបានទេ។ ទោះបីជាតាមរយៈចម្លើយរបស់សាក្សីធ្វើឲ្យតុលាការគិតថា ចុងចម្លើយបានសងបំណុលនោះរួចក៏ដោយ តែប្រសិនបើភាគីមិនបានអះអាងអំពីអង្គហេតុនេះទេ តុលាការមិនអាចយកការគិតឃើញរបស់ខ្លួននេះមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីលើអត្ថិភាព ឬ នត្ថិភាព ឬទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទបានឡើយ ក្នុងករណីនេះតុលាការត្រូវ

[៣៦] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

អនុវត្តសិទ្ធិបំភ្លឺ។ជាងនេះទៅទៀត ដើម្បីឲ្យតុលាការទទួលស្គាល់នូវការទាមទារតាមរយៈការអះអាង ភាគីត្រូវលើកឡើងអំពីការអង្គហេតុចម្បង ជាពិសេស គឺហេតុដែលជាមូលហេតុនៃការទាមទារ ដែលជាប្រភេទនៃអង្គហេតុចម្បង។ ក្នុងករណីដែលដើមចោទមិនអាចអះអាងអង្គហេតុអំពីកំណើតនៃសិទ្ធិបានគ្រប់គ្រាន់នោះទេ តុលាការអាចនឹងច្រានចោលការទាមទាររបស់ដើមចោទ។ ក្នុងករណីដែលចុងចម្លើយមិនយល់ព្រមនឹងការទាមទាររបស់ដើមចោទ ចុងចម្លើយមិនអាចទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទឬក៍អាចលើកឡើងនូវអង្គហេតុតវ៉ាបាន។ អង្គហេតុតវ៉ាជាប្រភេទនៃអង្គហេតុចម្បងរួមមាន៖ **អង្គហេតុរារាំងការកកើតសិទ្ធិ អង្គហេតុរលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ។**

### ៧.៥.ដំណាក់កាលនៃការអះអាង

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គេទទួលស្គាល់គោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ឲ្យតុលាការចេញសេចក្តីសម្រេចជាសាលក្រម។ដូចនេះ អង្គហេតុចម្បងដែលធ្វើជាមូលដ្ឋាននៃសាលក្រម គឺជាអង្គហេតុដែលភាគីអះអាងនៅក្នុងនីតិវិធីទាញហេតុផល ឬនីតិវិធីត្រៀមតែប៉ុណ្ណោះ ហើយប្រសិនបើភាគីមិនអះអាងអង្គហេតុនោះទេ តុលាការមិនអាចយកអង្គហេតុនោះមកធ្វើជាមូលដ្ឋានដើម្បីចេញសាលក្រមបានឡើយ។

### ៧.៦.ការទទួលខុសត្រូវក្នុងការអះអាង

គំនិតស្រដៀងគ្នាជាមួយការទទួលខុសត្រូវក្នុងការបញ្ជាក់ គឺ **ការទទួលខុសត្រូវក្នុងការអះអាង** ពីព្រោះក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គេទទួលស្គាល់គោលការណ៍ទាញហេតុផល ដូចនេះ អង្គហេតុចម្បងដែលអាចធ្វើជាមូលដ្ឋាននៃសាលក្រម គឺត្រឹមតែជាអង្គហេតុដែលភាគីអះអាងក្នុងនីតិវិធីទាញហេតុផល ឬនីតិវិធីត្រៀមតែប៉ុណ្ណោះហើយប្រសិនបើ ភាគីមិនអះអាងអង្គហេតុនោះទេ តុលាការ មិនអាចយកអង្គហេតុនោះ ធ្វើជាមូលដ្ឋានចេញសាលក្រមបានទេ។ ក្នុងករណី អង្គហេតុចម្បងណាមួយ ដែលជាមូលហេតុនៃការកើត ឡើងសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត មិនត្រូវបានអះអាងដោយភាគីបានទេ តុលាការ មិនអាចទទួលស្គាល់អង្គហេតុ នោះបានទេ ហើយក៍មិនអាចទទួលស្គាល់ការកើតឡើងនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលយកអង្គហេតុនោះ ជាមូលដ្ឋានឡើយ ដូចនេះហានិភ័យ ឬខូចផលប្រយោជន៍របស់ភាគីនេះ ត្រូវហៅថា **ការទទួលខុសត្រូវក្នុងការអះអាង ។** ទាក់ទងអង្គហេតុចម្បងណាមួយ ការទទួលខុសត្រូវក្នុងការអះអាង ភាគីដូចគ្នានឹងទទួលខុសត្រូវដោយសារតែទោះបីជាភាគីមិនអះអាងនូវអង្គហេតុណាមួយ ក៍ដោយ ឬទោះបីជាភាគីអះអាង និងមិនទទួលស្គាល់អង្គហេតុណាមួយក៍ដោយ ទំនាក់ទំនងគតិយុត្ត ឬសិទ្ធិដែលយកអង្គហេតុនោះធ្វើជាមូលដ្ឋាន មិនអាចទទួលស្គាល់

ដោយតុលាការបានទេ ដូចនេះហានិភ័យឬ ខូចផលប្រយោជន៍ ដូចគ្នានឹងការទទួលខុសត្រូវក្នុងការបញ្ជាក់ផងដែរ។

**ឧទាហរណ៍៖ ក្នុងករណី** ទាមទារតម្លៃផ្អែក លើកិច្ចសន្យាលក់-ទិញ ប្រសិនបើ ភាគីមិនអះអាងអំពីកិច្ចសន្យាលក់-ទិញទេ តុលាការ មិនអាចយកអង្គហេតុ នៃការលក់-ទិញ ធ្វើជាមូលដ្ឋាន ឬទោះបីជាភាគីអះអាងអង្គហេតុនោះក៏ដោយ បើតុលាការ មិនទទួលស្គាល់អង្គហេតុនោះទេ តុលាការ មិនទទួលស្គាល់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ ដោយយកអង្គហេតុនោះជាមូលដ្ឋានឡើយ។

### ៧.៧.អង្គហេតុដែលត្រូវការវាយតម្លៃ

ជាធម្មតា នៅក្នុងច្បាប់សារធាតុ មានចែងច្បាស់លាស់អំពីអង្គហេតុចម្បង ប៉ុន្តែករណីខ្លះ៖ អង្គហេតុចម្បង មិនត្រូវបានចែងឱ្យច្បាស់លាស់នៅក្នុងច្បាប់សារធាតុនោះទេ ហើយក៏មិនចែងអំពីអង្គហេតុជាក់ស្តែងដែរ តែបែរ ជាចែងលក្ខខណ្ឌដែលត្រូវវាយតម្លៃទៅវិញ ដូចជា កំហុស កំហុសធ្ងន់ធ្ងរ មូលហេតុត្រឹមត្រូវ ឬ លក្ខខណ្ឌដែល ខ្លឹមសារថា អាចយល់ដឹងការភាន់ច្រឡំ ឬ ឆបោក ឬ សណ្តាប់ធ្នាប់សាធារណៈ ឬភាពសុចរិត និងស្មោះត្រង់ ជាទី | (មាត្រា៤៦, ៧៤៣, ៩៤៦ និងមាត្រា៥ នៃក្រមរដ្ឋប្បវេណី)។ទាក់ទងនឹងកំហុសក្នុងអំពើអនីត្យានុកូល ទោះបីជាដើមចោទអះអាងអំពីអត្ថិភាពនៃកំហុស ក៏ដោយ ប្រសិនបើដើមចោទ មិនអខអាងអង្គហេតុជាក់ស្តែង ដែលជាមូលហេតុនៃកំហុសទេ ចៅក្រម មិនអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃកំហុសទេ ពីព្រោះ៖ កំហុស គឺជាលទ្ធផលនៃការវាយតម្លៃផ្អែកលើអង. ជាក់ស្តែង ដូចនេះ៖ ដើម្បីសម្រេចអំពីលក្ខខណ្ឌបែបនេន យើងត្រូវការអង្គហេតុជាក់ស្តែង ដែលគាំទ្រការវាយតម្លៃហើយភាគីអះអាងអង្គហេតុបែបនេះ៖ ចៅក្រមអាចវាយតម្លៃអង្គហេតុនោះបាន ។

ក្នុងករណីច្បាប់ចែងលក្ខខណ្ឌដែលត្រូវវាយតម្លៃ យើងអាចគិតថា អង្គហេតុជាក់ស្តែងដែលគាំទ្រ វាយតម្លៃ គឺជាអង្គហេតុចម្បង ហើយលក្ខខណ្ឌលត្រូវវាយតម្លៃ ជាលទ្ធផលនៃការវាយតម្លៃប៉ុណ្ណោះ ។ ឧទាហរណ៍ ពេល Y ជិះកង់បានប៉ះទង្គិចគ្នាជាមួយX បណ្តាលឱ្យ X រងរបួស ក្នុងករណី X ទាមទារសំណងនៃ ការខូចខាតផ្អែកលើ អំពើអនីត្យានុកូល X ត្រូវការអះអាងអង្គហេតុជាក់ស្តែង ដែលខ្លឹមសារថា Y មិនមើលមុខមើលក្រោយមិនប្រើប្រាស់ ភ្លើងបំភ្លឺ ទោះបីជាយប់ងងឹតក៏ដាយ ។ ប្រសិនបើ X មិនអះអាងអង្គហេតុជាក់ស្តែងទេ តុលាការ មិនអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃកំហុសឡើយ ក្នុងករណីនេះ៖ អង្គហេតុ ដែលខ្លឹមសារថា X មិនមើលមុខ មើលក្រោយ ឬមិនប្រើប្រាស់ភ្លើងបំភ្លឺ គឺជាអង្គហេតុចម្បងដែលគាំទ្រការវាយតម្លៃ ។ ចំណែក អង្គហេតុដែល ខ្លឹមសារថា នៅតាមផ្លូវនោះ៖ មានភ្លើងបំភ្លឺ ទោះបីមិនប្រើប្រាស់ភ្លើងកង់ក៏ដោយ អាចមើលឃើញច្បាស់លាស់ ឬ X ចេញទៅមក

ភ្លាមៗ គឺជាអង្គហេតុចម្បង បដិសេធការវាយតម្លៃចំពោះនកំហុស ។ ក្នុងករណីឧទាហរណ៍នេះ៖ ប្រសិនបើតុលាការ ទទួលស្គាល់អង្គហេតុដែលភាគីមិនអះអាង ដូចជា កង់របស់ Y មានវិការៈជាអាទី ហើយចេញសាលក្រម សាលក្រមនេះ៖ ផ្ទុយនឹងគោលការណ៍ទាញហេតុផល ( មានត្រា៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### ៧.៨ ការបញ្ជាក់(ភស្តុតាង និង អង្គហេតុ)

### ៧.៩. អត្ថន័យ និងភាពចាំបាច់ក្នុងការទទួលខុសត្រូវក្នុងការបញ្ជាក់

ភាគីដែលអះអាងនៅអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលជាការកើតឡើងនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ក្នុងករណីប្រសិនបើ ចៅក្រមអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនៃអង្គហេតុនោះច្បាស់លាស់ គ្មានបញ្ហាអ្វីនោះទេ។ប៉ុន្តែអង្គហេតុបែបនេះ ជាអង្គហេតុកើតឡើងពី អតីតកាលទោះបីជាតុលាការពិនិត្យមើលដោយភស្តុតាងក៏ដោយ ករណីខ្លះតុលាការ មិនអាចយល់ដឹងអំពី អត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះទេ។ ប៉ុន្តែទោះបីជាចៅក្រម មិនអាចយល់ដឹងអំពីអង្គហេតុចម្បង ក៏ដោយ ចៅក្រមមិនអាចបដិសេធមិនចេញសាលក្រមបានទេ ពីព្រោះតុលាការជាស្ថាប័នត្រូវចេញសាលក្រម ប្រសិនបើមានការដាក់ពាក្យបណ្តឹង និងក្រៅពីបណ្តឹងនោះបញ្ចប់ដោយឆន្ទៈនៃភាគី ផ្ទុយទៅវិញ ប្រសិនបើតុលាការ មិនចេញសាលក្រមទេតុលាការមិនអាចដោះស្រាយបញ្ហាបានឡើយ។គ្រប់អង្គហេតុ និងភស្តុតាងសុទ្ធតែមានអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់មានន័យថាភាគីត្រូវធ្វើការបញ្ជាក់អង្គហេតុដោយភស្តុតាង ឬបង្ហាញថាភស្តុតាងមួយជាភស្តុតាងពិតប្រាកដ ភាគីត្រូវបញ្ជាក់បង្ហាញអំពីអង្គហេតុពិតណាមួយដែលមានភាពទាក់ទងជាមួយនឹងភស្តុតាងនោះ។

**ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទទាមទារឲ្យចុងចម្លើយសងប្រាក់កម្ចីផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដើមចោទត្រូវអះអាងអំពីការព្រមព្រៀងសង ការប្រគល់ប្រាក់ដោយផ្អែកលើការព្រមព្រៀងនោះ និងពេលកំណត់សងបានមកដល់។ ប្រសិនបើដើមចោទមិនអាចបញ្ជាក់នូវអង្គហេតុណាមួយក្នុងចំណោមអង្គហេតុទាំងបីខាងលើនេះ ដោយបង្ហាញអំពីភស្តុតាងមួយចំនួនដូចជា លិខិតបង្កើតកិច្ចសន្យាខ្ចីបរិភោគ ឬ សាក្សីដែលបានចូលរួមក្នុងការបង្កើតកិច្ចសន្យានោះទេ តុលាការមិនអាចទទួលស្គាល់នូវការកើតឡើងនូវសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនោះបានទេ។**ហេតុដូចនេះហើយ ភាគីដែលបានអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលជាការកើតឡើងនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ចាំបាច់ត្រូវធ្វើការបញ្ជាក់អង្គហេតុនោះដោយភស្តុតាងដើម្បីធ្វើឲ្យតុលាការអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ ដើម្បីឈានទៅដល់ការចេញនូវសេចក្តីសម្រេច ក្នុងការបញ្ចប់នូវវិវាទដែលបានកើតឡើងនោះ។

### ៧.៩.១.វិធីបញ្ជាក់ភស្តុតាងនៃអង្គហេតុ

ដើម្បីធ្វើការបញ្ជាក់ភស្តុតាងនៃអង្គហេតុ គេមានវិធីពីរយ៉ាង។វិធីទីមួយ គឺការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុ វិធីទីពីរ គឺការទទួលស្គាល់នូវអង្គហេតុប្រយោលតាមរយៈភស្តុតាងប្រយោល។ បើសិនជាកខ្វះខាតនូវភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អង្គហេតុចម្បង ដើមចោទគប្បីសរសេរក្នុងពាក្យបណ្ដឹងនូវអង្គហេតុប្រយោលឲ្យបានច្រើន។ ផ្ទុយទៅវិញ ប្រសិនបើមានភស្តុតាងច្បាស់លាស់ហើយ គេមិនចាំបាច់សរសេរអង្គហេតុប្រាសក៏បានដែរ។

ឧទាហរណ៍៖ ដើម្បីបញ្ជាក់ពីអង្គហេតុចម្បង ក បានឲ្យប្រាក់ ខ ខ្ចីចំនួន ១០០០ ដុល្លា ដើមចោទអាចអះអាងនូវអង្គហេតុប្រយោល ដូចតទៅ៖ ក បានមកដកប្រាក់នៅធនាគារចំនួន ១០០០ ដុល្លារ មុនពេលឲ្យប្រាក់ទៅ ខ ខ្ចី ហើយ ខ បានទិញម៉ូតូមួយគ្រឿងក្នុងតម្លៃប្រហែល ១០០០ ដុល្លារ ក្រោយពេលឲ្យខ្ចីប្រាក់។

ការបញ្ជាក់ភស្តុតាង ត្រូវធ្វើនៅដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់តាមរយៈការស្នើសុំរបស់ភាគីបន្ទាប់មកតុលាការធ្វើការសម្រេចថាទទួលយកសំណើរ ឬមិនទទួលយក ឬករណីប្រសិនបើមានភាពចាំបាច់តុលាការអាចធ្វើការពិនិត្យភស្តុតាងតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

### ៧.៩.២.ការទទួលខុសត្រូវក្នុងការបញ្ជាក់

### ៧.៩.៣.អត្ថន័យនៃការទទួលខុសត្រូវក្នុងការបញ្ជាក់

នៅក្នុងនីតិវិធីនៃបណ្ដឹង អាចមានករណីដែល ទោះបីជាបានធ្វើការជម្រះក្ដីដោយហ្មត់ចត់យ៉ាងណាក៏ដោយក៏មិនអាចទទួលស្គាល់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលចាំបាច់សម្រាប់កំណត់អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលបានអះអាងដោយដើមចោទ នៅក្នុងបណ្ដឹងបានដែរ។ នៅក្នុងករណីបែបនេះ ប្រសិនបើអនុញ្ញាតឲ្យតុលាការបញ្ចប់នីតិវិធីនៃបណ្ដឹងដោយមិនចេញសាលក្រម ដោយសំអាងថាមិនអាចកំណត់អត្ថិភាពឬនត្ថិភាពនៃសិទ្ធិបាន ព្រោះអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ មានភាពមិនច្បាស់លាស់នោះ វិវាទរវាងភាគី មិនអាចដោះស្រាយបានឡើយ ហើយក៏មិនអាចផ្ដល់ការសង្គ្រោះដល់ភាគីដែលមានសិទ្ធិនោះដែរ។ ហេតុនេះហើយទោះបីក្នុងករណីបែបនេះក៏ដោយ ដើម្បីអាចចេញសាលក្រមបាន ប្រព័ន្ធនៃការកំណត់ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានបង្កើតឡើងដើម្បីអានុភាពគតិយុត្តបានដោយធ្វើការសន្មតអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ។

មានន័យថាក្នុងករណីដែលអង្គហេតុចាំបាច់ដើម្បីកំណត់អំពិអត្ថិភាព ឬ នត្ថិភាពនៃអានុភាពគតិយុត្តណាមួយ( ឧទាហរណ៍ដូចជា ការកកើត ឬ ការរលត់សិទ្ធិ ) មិនអាចកំណត់បាននៅក្នុងបណ្ដឹងទេនោះប្រព័ន្ធនៃការកំណត់ការទទួលខុសត្រូវក្នុងការបញ្ជាក់ អាចផ្ដល់លទ្ធភាពឲ្យគេអាចសម្រេចអំពីការបានបង្កើត ឬមិនបាន

បង្កើតនូវអានុភាពគតិយុត្តនោះបាន ដោយសន្មតថាវាធ្វើឲ្យខូចផលប្រយោជន៍ដល់ភាគីណាមួយ ហើយធ្វើបែបនេះ តុលាការនឹងអាចចេញសេចក្តីសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិបាន។នៅក្នុងប្រព័ន្ធនេះប្រសិនបើអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុណាមួយ ត្រូវបានសន្មតថានឹងធ្វើឲ្យខូចប្រយោជន៍ដល់ភាគីណាម្ខាងភាគីនោះត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុនោះ។ នេះគឺចេញមកពីគំនិតដែលថា ទោះជាភាគីត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ក៏ដោយ បើភាគីមិនបានធ្វើការបញ្ជាក់នោះទេ ហេតុនេះហើយបានជាអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះ ត្រូវបានសន្មត ដោយធ្វើឲ្យខូចប្រយោជន៍ដល់ភាគីនោះ ។ក៏ប៉ុន្តែ នៅក្នុងករណីជាក់ស្តែង ការទទួលខុសត្រូវក្នុងការបញ្ជាក់ គឺជាការទទួលខុសត្រូវលើលទ្ធផល ដែលមិនសុទ្ធតែផ្អែកទៅលើកំហុស ឬ ការធ្វេសប្រហែសរបស់ភាគីដែលមានបន្ទុក នៅក្នុងការដាក់ភស្តុតាងឡើយ។

ដោយសារថា ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានប្រើប្រាស់ នៅក្នុងករណីដែលអត្ថិភាព ឬនិត្ថិភាពនៃអង្គហេតុណាមួយ នៅតែមានភាពមិនច្បាស់លាស់ បើទោះបីជាបានធ្វើការពិនិត្យភស្តុតាងដោយហ្មត់ចត់យ៉ាងណាក៏ដោយ ដូច្នេះហើយ ត្រូវកំណត់ថាតើដើមចោទ ឬចុងចម្លើយ ដែលត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់នៅក្នុងបណ្តឹង។ ចំពោះអង្គហេតុតែមួយ មិនអាចមានករណីដែលដើមចោទត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អត្ថិភាព ហើយចុងចម្លើយត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់នត្ថិភាពនៃអង្គហេតុដដែលនោះទេ។នៅក្នុងករណីដែលមានវិវាទអំពីអត្ថិភាព ឬនិត្ថិភាពនៃអង្គហេតុណាមួយនៅក្នុងបណ្តឹង ភាគីទាំងសងខាង នឹងដាក់ភស្តុតាងដើម្បីបញ្ជាក់ថា ការអះអាងអង្គហេតុរបស់ខ្លួន ជាការពិត ឬមិនពិត។ ចំពោះភាគីដែលត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុនោះ មិនអាចសម្រេចគោលបំណងបានឡើយ ប្រសិនបើមិនអាចធ្វើឲ្យចៅក្រមជឿទុកចិត្តថាការអះអាងរបស់ខ្លួនគឺជាការពិតទេនោះ។ផ្ទុយទៅវិញ ដោយយោងទៅតាមការទទួលខុសត្រូវក្នុងការបញ្ជាក់ ភាគីម្ខាងទៀតអាចសម្រេចនូវគោលបំណងរបស់ខ្លួនបាន ដោយការធ្វើឲ្យចៅក្រមមានភាពមិនច្បាស់លាស់អំពីអត្ថិភាពនៃអង្គហេតុនោះ គឺមិនចាំបាច់ធ្វើឲ្យចៅក្រមជឿទុកចិត្តថា សេចក្តីថ្លែងការណ៍របស់ខ្លួនគឺជាការពិតនោះទេ។ដូចបានពន្យល់ពីខាងដើម ភស្តុតាងដែលភាគីដែលមានការទទួលខុសត្រូវក្នុងការបញ្ជាក់ត្រូវដាក់ហៅថា “ភស្តុតាងស្រប” ចំណែកឯភស្តុតាងដែលភាគីម្ខាងទៀតត្រូវដាក់ហៅថា “ភស្តុតាងផ្ទុយ”។

ការទទួលខុសត្រូវក្នុងការបញ្ជាក់ ដែលមានន័យខុសគ្នាពីការទទួលខុសត្រូវក្នុងការអះអាង មិនមែនជាលក្ខណៈពិសេសនៃគោលការណ៍នៃការទាញហេតុផលឡើយ។ តាមប្រព័ន្ធតុលាការដែលយកគោលការណ៍នៃការស្វែងរកអង្គហេតុដោយឆន្ទានុសិទ្ធិរបស់ចៅក្រម ដែលតុលាការធ្វើការស្រាវជ្រាវអំពីអង្គហេតុ និងពិនិត្យភស្តុ

តាង តាមឆន្ទានុសិទ្ធិរបស់ខ្លួននោះ ក៏អាចមានករណីបែបនេះ ក៏ចាំបាច់ត្រូវធ្វើការសន្មតអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះ តាមរយៈការទទួលខុសត្រូវក្នុងការបញ្ជាក់ដែរ។

### ៧.៩.៤.ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

បញ្ញត្តិនៃច្បាប់ដែលកំណត់ថាតើភាគីណាមួយដែលត្រូវមានការទទួលខុសត្រូវក្នុងការបញ្ជាក់ ហៅថា "**ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់**" ។ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ មិនត្រូវបានធ្វើឡើងដោយផ្អែកទៅលើលក្ខណៈនៃអង្គហេតុដែលពាក់ព័ន្ធនោះទេ។ ការកំណត់នេះ ត្រូវធ្វើឡើងដោយផ្អែកលើមធ្យោបាយនៃការកំណត់ល័ក្ខខ័ណ្ឌគតិយុត្តនៃបញ្ញត្តិច្បាប់ ដើម្បីធ្វើការសម្រេចទៅលើអានុភាពគតិយុត្តនៃការបង្កើត ឬ ការរលត់សិទ្ធិណាមួយ។ មានន័យថា បញ្ញត្តិច្បាប់សារធាតុនីមួយៗ មានចែងអំពីល័ក្ខខ័ណ្ឌគតិយុត្តនានា ដើម្បីឲ្យអានុភាពគតិយុត្តណាមួយកើតឡើង ហើយតាមរយៈនេះ គេដឹងថា បញ្ញត្តិច្បាប់សារធាតុនោះ មានគោលគំនិតថា ប្រសិនបើអង្គហេតុណាមួយដែលបានឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌគតិយុត្តទាំងនោះកើតមានឡើង នោះអានុភាពគតិយុត្តដែលមានចែង ត្រូវកើតឡើង។ អាស្រ័យហេតុនេះហើយក្នុងករណីដែលមានបញ្ញត្តិដែលចែងយ៉ាងច្បាស់នៅក្នុងច្បាប់សារធាតុ ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវយោងទៅតាមបញ្ញត្តិនោះ។ ហើយប្រសិនបើពុំមានបញ្ញត្តិចែងច្បាស់លាស់ទេ ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ជាគោលការណ៍ត្រូវធ្វើឡើងដោយផ្អែកលើលំដាប់សមហេតុផលនៃការអនុវត្តបញ្ញត្តិច្បាប់សារធាតុ និងទៅតាមវិធីនៃការ កំណត់លក្ខខ័ណ្ឌគតិយុត្ត នៅក្នុងបញ្ញត្តិច្បាប់សារធាតុនីមួយៗ ។ ជាក់ស្តែង ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានកំណត់ដោយគិតពិចារណាអំពីគោលនយោបាយ ដូចជាសមធម៌រវាងភាគីទាំងពីនៅក្នុងដំណើររឿងក្តី ការដោះស្រាយវិវាទឲ្យបានឆាប់រហ័ស ឬ មានភាពងាយស្រួលក្នុងការអះអាងអំពីសិទ្ធិនៅក្នុងនីតិវិធីនៃបណ្តឹង ជាអាទិ៍។ អាស្រ័យហេតុនេះហើយ ក្នុងករណីដែលពុំមានភាពច្បាស់លាស់ថា តើអង្គហេតុណាមួយដេលច្បាប់សារធាតុកំណត់ថាជាលក្ខខ័ណ្ឌគតិយុត្ត ដើម្បីឲ្យមានអានុភាពគតិយុត្តណាមួយកើតឡើង ហើយការបញ្ជាក់ត្រូវធ្វើឡើងដោយផ្អែកលើការបកស្រាយនោះ ខ្លឹមសារនៃច្បាប់សារធាតុនោះ និង ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវកំណត់ដោយផ្អែកលើការពិចារណាអំពីចំណុចទាំងអស់នេះ។

គោលការណ៍នៃក្រមនីតិរដ្ឋប្បវេណីបានចែងថា អ្នកដែលទទួលផលប្រយោជន៍ពីការកកើតឡើងនូវទំនាក់ទំនងកតិយុត្តមានករណីកិច្ចត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់។ ចំពោះអង្គហេតុដែលជាមូលហេតុនៃការកកើតឡើងនូវសិទ្ធិ ភាគីដែលបានលើកឡើងនូវសិទ្ធិ ភាគីដែលបានលើកឡើងពីអង្គហេតុនេះ ជាអ្នកទទួលខុស

ត្រូវក្នុងការបញ្ជាក់។ ក៏ដូចគ្នាដែរ ចំពោះអង្គហេតុរារាំង ឬរំលត់សិទ្ធិ ឬទប់ស្កាត់ការប្រើប្រាស់សិទ្ធិភាគីដែលបានលើកឡើងនូវអង្គហេតុទាំងនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់។

ដើម្បីចេញសាលក្រម តុលាការត្រូវពិចារណាទៅលើអង្គហេតុដែលកើតមានដើម្បីផ្គូរផ្គងនឹងច្បាប់។ អង្គហេតុត្រូវបានទទួលស្គាល់ដោយតុលាការ តាមរយៈការសារភាព ឬតុលាការអាចទទួលស្គាល់អង្គហេតុដែលមានវិវាទតាមរយៈភស្តុតាង ដែលភាគីទទួលខុសត្រូវក្នុងការបញ្ជាក់តាមរយៈការស្នើសុំឲ្យពិនិត្យ។បើទោះបីជាតុលាការពិនិត្យមើលភស្តុតាងរួចហើយក៏ដោយ បើសិនជាតុលាការមិនអាចយល់ដឹងបានថា អង្គហេតុនោះពិតជាមាននោះទេ តុលាការនឹងសន្មត់ថាអង្គហេតុនោះអត់មាន។ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលភាគីត្រូវធ្វើការបញ្ជាក់អង្គហេតុឲ្យកាន់តែច្បាស់ថែមទៀត ដើម្បីអាចឲ្យតុលាការទទួលស្គាល់អង្គហេតុ និងអាចសម្រេចតាមការទាមទាររបស់ភាគីណាមួយនោះ។

### ៧.៩.៥.ការសន្មតតាមផ្លូវច្បាប់ និងការពិតជាបណ្ដោះអាសន្ន

ជាគោលការណ៍_ភាគីត្រូវការអូនអាងអង្គហេតុទាំងអស់ ដែលជាមូលហេតុនៃការកើតឡើងទំនាក់ទំនងគតិយុត្តនៃផលប្រយោជន៍របស់ខ្លួន និងត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ចំពោះអង្គហេតុដែលខ្លួនអះអាង ប៉ុន្តែករណីខ្លះ ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានបន្ថយ ដោយមធ្យោបាយពីរយ៉ាង ហៅថា **ការសន្មតតាមច្បាប់ និងការពិតជាបណ្ដោះអាសន្ន** ។

(១) ការសន្មតតាមផ្លូវច្បាប់ គឺជាការសន្មតក្នុងករណីដែលបញ្ញត្តិច្បាប់ចែងថា ក្នុងករណីដែលមានអង្គហេត ក៏ត្រូវសន្មតថា មានអង្គហេតុ"ខ" ។ ការសន្មតតាមផ្លូវច្បាប់ ត្រូវបានបង្កើតឡើងក្នុងគោលបំណង ទទួលស្គាល់ នូវការកើតឡើងនូវអានុភាពគិតយុត្តដែលកំណត់ដោយច្បាប់ ក្នុងករណីដែលមានការលំបាកនឹងធ្វើការបញ្ជាក់សីពីលក្ខខណ្ឌគតិយុត្តនៃច្បាប់មួយ ដូចនេះៈ ការសន្មតតាមផ្លូវច្បាប់ មានន័យថា ប្រសិនបើ អាចបញ្ជាក់អង្គហេតុដទៃ នឹងមានន័យដូចគ្នានឹងការបញ្ជាក់អង្គហេតុដែលជាលក្ខខណ្ឌគតិយុត្តដែរ ។ ការសន្មតតាមផ្លូវច្បាប់ត្រូវបានបែង ចែកជាពីរប្រភេទ គឺ ការសន្មតតាមផ្លូវច្បាប់ចំពោនអង្គហេតុ និងការសន្មតតាមផ្លូវ ច្បាប់ចំពោះសិទ្ធិ ។ ឧទាហរណ៍ នៃការសន្មតតាមផ្លូវច្បាប់ចំពោះអង្គហេតុ ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុដោយអាជ្ញាយុកាល អ្នកអះអាងលទ្ធកម្មដោយអាជ្ញាយុកាល ត្រូវការបញ្ជាក់ថា ការកាន់កាប់ រហូតដល់១០ ឬ២០ឆ្នាំ ប៉ុន្តែ ជាធម្មតាការបញ្ជាក់ អំពីការកាន់រហូត១០ឆ្នាំ ឬ២០ឆ្នាំ ជាចំណុចពិបាកក្នុងការបញ្ជាក់ ដូចនេះៈ ដើម្បីបន្ថយការទទួលខុសត្រូវ ក្នុងការបញ្ជាក់ មាត្រា២៣៤ កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណី ចែងថា ប្រសិនបើមានភស្តុតាងដែលបញ្ជាក់ថាបានកាន់កាប់នៅពេលមួយ និងនៅពេលមួយផ្សេងទៀតដែលក្រោយពេលនោះអ្នកកាន់កាប់នោះ

ត្រូវសន្មតថាកាប់កាន់កាប់ជាប់រហូតក្នុងអំឡុងពេលនោះ ។ ឧទាហរណ៍ នៃការសន្មតតាមផ្លូវច្បាប់ចំពោះសិទ្ធិ ត្រូវបានចែងនៅ ក្នុងមាត្រា២៣៤ កថាខណ្ឌទី៤នៃក្រមរដ្ឋប្បវេណីដែល ខ្លឹមសារថា អ្នកកាន់កាប់ ត្រូវបានសន្មតថា មានសិទ្ធ ត្រឹមត្រូវស្របច្បាប់ក្នុងការកាន់កាប់វត្ថុ ។

(**២**) ការពិតជាបណ្តោះអាសន្ន គឺករណីដែលអង្គហេតុចម្បងមួយសន្មតអត្ថិភាពនៃអង្គហេតុចម្បង ផ្សេងទៀត ឧទាហរណ៍នៃការពិតបណ្តោះអាសន្ន មានចែងនៅក្នុងមាត្រា២៣៤ កថាខណ្ឌទី១ និងទី២នៃក្រមរដ្ឋប្បវេណី។

[៣៧] មាត្រា២៣៤ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៣៨] មាត្រា២៣៤ កថាខណ្ឌកថាខណ្ឌទី១ និងទី២

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងប្រធានបទស្តីពី អំពីពាក្យបណ្តឹង អស់រយៈពេលមួយរយៈកន្លងមក យើងអាចធ្វើការសន្និដ្ឋានដូចតទៅ៖ ជាការពិតណាស់ ដើម្បីរៀបចំនៅចំណុចវិវាទប្រព្រឹត្តទៅដោយរលូន ភាគីក្នុងរឿងក្តីរដ្ឋប្បវេណីត្រូវស្វែងយល់ជាចាំបាច់អំពីអង្គហេតុវិវាទជាមុនសិន ដើម្បីងាយស្រួលនឹងរៀបចំសរសេរក្នុងពាក្យបណ្តឹងដាក់ជូនតុលាការ។ប្រសិនបើយើងធ្វើការបែងចែកឲ្យបានច្បាស់រវាងប្រភេទនៃអង្គហេតុជាមួយនឹងប្រភេទបណ្តឹងដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នោះយើងនឹងងាយស្រួលក្នុងការសរសេរពាក្យបណ្តឹងបានច្បាស់លាស់ នូវចំណុចវិវាទ និងបង្កភាពងាយស្រួលដល់តុលាការដំណើរការរឿងក្តី និងឈានទៅដល់ការសម្រេចសេចក្តី។

តាមរយៈប្រធានបទខាងលើ អង្គហេតុចម្បងត្រូវបានគេចាត់ទុកជាអង្គហេតុមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលគូភាគីបានអះអាងនៅក្នុងការថ្លែងការរបស់ខ្លួន។ ដើម្បីអាចឲ្យតុលាការទទួលស្គាល់នូវអង្គហេតុដែលភាគីបានលើកឡើងតុលាការត្រូវធ្វើការពិចារណាដោយផ្អែកទៅលើភស្តុតាងនៃអង្គហេតុនោះ ថាតើអង្គហេតុនោះបានបញ្ជាក់អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងដែរឬទេ។អង្គហេតុចម្បងត្រូវបានបែងចែកជា ៤(បួន)ប្រភេទ ទៅតាមស្តង់ដារនៃបញ្ញត្តិច្បាប់សារធាតុទៅតាមមុខងារនៃអានុភាពគតិយុត្ត ដូចជា៖អង្គហេតុនៃកំណើតសិទ្ធិ(បទបញ្ញត្តិចែងលក្ខខណ្ឌនៃកំណើតសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត) អង្គហេតុនៃឧបសគ្គសិទ្ធិ(បទបញ្ញត្តិចែងអំពីឧបសគ្គនៃសិទ្ធិ) អង្គហេតុរំលត់សិទ្ធិ(បទបញ្ញត្តិចែងអំពីលក្ខខណ្ឌនៃការរលត់សិទ្ធិដែលបានកើតឡើង) និងអង្គហេតុរារាំងសិទ្ធិ (បទបញ្ញត្តិចែងអំពីការរារាំងការអនុវត្តសិទ្ធិមួយរយៈពេល)។

សរុបសេចក្តីមក ការស្វែងយល់អំពីអង្គហេតុ គឺជាការចាំបាច់បំផុតមុនឈានទៅដល់ការសរសេរពាក្យបណ្តឹង ដោយហេតុថា អង្គហេតុក្នុងក្តីរដ្ឋប្បវេណីមានច្រើនប្រភេទដូចដែលបានរៀបរាប់ខាងលើ។ នៅក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា មានអ្នកប្រកបវិជ្ជាជីវៈ និងអ្នកអនុវត្តច្បាប់មួយចំនួន ហាក់បីដូចជាមិនសូវយកចិត្តទុកដាក់ និងធ្វើការស្វែងយល់អំពីប្រភេទនៃអង្គហេតុ និងទម្រង់នៃពាក្យបណ្តឹងដូចដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាននោះទេ។ដោយករណីខ្លះ ភាគីមិនបានបញ្ជាក់ទាក់ទងទៅនឹងអត្តសញ្ញាណ ឬ ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ ដែលមិនមានផលប្រយោជន៍នៃបណ្តឹង។កត្តាទាំងអស់នេះហើយ ដែលធ្វើឲ្យស្ថាប័នតុលាការមិនអាចដំណើរការនីតិវិធីបានដោយរលូន ហើយជាហេតុដែលតុលាការបង្គាប់ឲ្យភាគីធ្វើការកែតម្រូវ ឬ អាចលើកបណ្តឹងចោល។

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ និងប្រធានបទស្តីពី អំពីពាក្យបណ្តឹង អស់រយៈពេលមួយរយៈកន្លងមក យើងអាចសង្កេតឃើញថាៈ ជាការពិតណាស់ ដើម្បីរៀបចំនៅចំណុចវិវាទប្រព្រឹត្តទៅដោយរលូន ភាគីក្នុងរឿងក្តីរដ្ឋប្បវេណីត្រូវស្វែងយល់ជាចាំបាច់អំពីអង្គហេតុវិវាទជាមុនសិន ដើម្បីងាយស្រួលនឹងរៀបចំសរសេរក្នុងពាក្យបណ្តឹងដាក់ជូនតុលាការ។ប្រសិនបើយើងធ្វើការបែងចែកឲ្យបានច្បាស់រវាងប្រភេទនៃអង្គហេតុជាមួយនឹងប្រភេទបណ្តឹងដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នោះយើងនឹងងាយស្រួលក្នុងការសរសេរពាក្យបណ្តឹងបានច្បាស់លាស់ នូវចំណុចវិវាទ និងបង្កភាពងាយស្រួលដល់តុលាការដំណើរការរឿងក្តី និងឈានទៅដល់ការសម្រេចសេចក្តី។

នៅក្នុងពាក្យបណ្តឹង ភាគី ឬអ្នកតំណាងដោយអាណត្តិ ត្រូវសរសេរឲ្យបានច្បាស់លាស់នូវអត្តសញ្ញាណ និងអាសយដ្ឋានរបស់គូភាគី (ទាំងភាគីដើមចោទ និងចុងចម្លើយ) និងអត្តសញ្ញាណ អាសយដ្ឋានរបស់អ្នកតំណាង(បើមាន)។ភាគីត្រូវសរសេរអំពីចំណុចដែលខ្លួនចង់ទាមទារឲ្យលាការចេញ មានន័យថាខ្លឹមសារនៃសាលក្រមដេលទាមទារឲ្យតុលាការចេញឲ្យបានច្បាស់លាស់ ពីព្រោះ តុលាការចេញសេចក្តីសម្រេចដោយផ្អែកទៅលើការទាមទាររបស់ភាគីប៉ុណ្ណោះ ។ ហើយចំណុចមួយទៀតដែលភាគីត្រូវសរសេរជាចាំបាច់ផងដែរ គឺអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ពីព្រោះវាជាអង្គហេតុមូលដ្ឋាន ឬជាសំអាងសម្រាប់ធ្វើការទាមទារ។ បើទោះបី ភាគីមិនបានសរសេរ ឬដាក់បញ្ចូលក្នុងពាក្យបណ្តឹងក៏ដោយ ក៏មិនមែនជាមូលហេតុដែលតុលាការលើកបណ្តឹងចោល ឬបង្គាប់ឲ្យកែតម្រូវដែរ។ ប៉ុន្តែដើម្បីឲ្យតុលាការងាយស្រួលស្វែងយល់ពីបណ្តឹងឲ្យបានច្បាស់លាស់ ភាគីគប្បីសរសេរ និងដាក់បញ្ចូលឲ្យហើយ ជៀសសសរៀង ការបង្អាក់ដំណើរការនៃនីតិវិធីប្រព្រឹត្តទៅមិនបានរលូន។

ជាអវសាន នាងខ្ញុំសង្ឃឹមថា ទៅថ្ងៃអនាគតនៅពេលដែលប្រជាជនមានការយល់ដឹងកាន់តែច្បាស់ និងស្វែងយល់ឲ្យបានច្បាស់អំពីការសរសេរពាក្យបណ្តឹង និងអង្គហេតុជាមូលដ្ឋានក្នុងការទាមទារដើម្បីជៀសវាងការបង្អាក់ដំណើរការនៃនីតិវិធីប្រព្រឹត្តទៅមិនរលូនដែលនាំឲ្យមានការយឺតយ៉ាវក្នុងការដំណើររឿងក្តី។

## ឯកសារយោង

### • ច្បាប់ និង បទបញ្ញត្តិផ្សេងៗ

១. ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៧។

២. ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### • សៀវភៅ និង ឯកសារផ្សេងៗ

៣. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ ស្តីពី " *នីតិវិធីបណ្តឹង* "។

៤. ឯកសារតុលាការស្តីពី "*អង្គហេតុចម្បង និងការសរសេរពាក្យបណ្តឹង*" រៀបចំដោយមេធាវី **អៀង សំអាង** កាលបរិច្ឆេទថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥។

៥. ឯកសារសិក្ខាសាលាស្តីពី "អង្គហេតុចម្បងដែលជាធាតុផ្សំ"

៦. ឯកសារសិក្ខាសាលាស្តីពី ការសរសេរពាក្យបណ្តឹង និងឯកសារត្រៀម

៧. សៀវភៅមេរៀនស្តីពី "មូលដ្ឋាននៃអង្គហេតុចម្បង"

៨. សៀវភៅស្តីពី "ការពន្យល់អំពីនីតិវិធីជំនុំជម្រះលើកទី១" ដែលបានបោះពុម្ពលើកទី២ ខែវិច្ឆិកា ឆ្នាំ ២០១៥។

## បញ្ជីឧបសម្ព័ន្ធ

### ១.គំរូពាក្យបណ្តឹង

- ពាក្យបណ្តឹងធម្មតា
- ពាក្យបណ្តឹងទាមទារប្រាក់
- ពាក្យបណ្តឹងទាមទារដី
- ពាក្យបណ្តឹងលែងលះ

### ២.គំរូសាលក្រមរដ្ឋប្បវេណី

📖

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹង(ឧទ្ធរណ៍)

**<u>ដើមចោទ៖</u>** ឈ្មោះ ......................... ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... មានអាសយដ្ឋានបច្ចុប្បន្ន
នៅផ្ទះ........... ផ្លូវ.......... ភូមិ............... ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ...............
រាជធានី/ខេត្ត..........................។

**<u>ចុងចម្លើយ៖</u>** ឈ្មោះ ......................... ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... មានអាសយដ្ឋានបច្ចុប្បន្ន
នៅផ្ទះ........... ផ្លូវ.......... ភូមិ............... ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ...............
រាជធានី/ខេត្ត..........................។

## សូមគោរពចូលមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក.<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖</u>**

១. ...........................................................................................................។
២. ...........................................................................................................។
៣. ...........................................................................................................។

**ខ.<u>អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារ</u>**

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ .......................................
.......................................................................................................................
.......................................................................................................................
.......................................................................................................................
.......................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សម្រេចតាមការទាមទាររបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............ .......កើត/រោច ខែ........... ឆ្នាំ......... ពុទ្ធសករាជ................
ធ្វើនៅ...................., ថ្ងៃទី...... ខែ........... ឆ្នាំ...........

**ស្នាមមេដៃស្ដាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹង(ទាមទារប្រាក់)

**<u>ដើមចោទ៖</u>** ឈ្មោះ ........................ ភេទ........... កើតឆ្នាំ............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ........... ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ............... រាជធានី/ខេត្ត...........................។

**<u>ចុងចម្លើយ៖</u>** ឈ្មោះ ........................ ភេទ........... កើតឆ្នាំ............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ........... ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ............... រាជធានី/ខេត្ត...........................។

## សូមគោរពចូលមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ក.<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖</u>

១. បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន.....................(.....................)រៀល ឱ្យមកខ្ញុំបាទ/នាងខ្ញុំ ។

២. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ចំនួន............................(............................)រៀល ឱ្យមកខ្ញុំបាទ/នាងខ្ញុំ ។

៣. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់យឺតយ៉ាវចំនួន.......................(.......................)រៀល ឱ្យមកខ្ញុំបាទ/នាងខ្ញុំ ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

### ខ.<u>អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារ</u>

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីអំឡុងឆ្នាំ.............. ឈ្មោះ.................. ដែលជាចុងចម្លើយ បានខ្ចីប្រាក់ពីខ្ញុំបាទ/នាងខ្ញុំ ចំនួន.................(.....................)រៀល ដោយកំណត់រយៈពេល........ឆ្នាំ តាមរយៈកិច្ចសន្យាខ្ចីចងការប្រាក់ ប៉ុន្តែនៅថ្ងៃដែលបានកំណត់អំពីការសងប្រាក់មកដល់ ចុងចម្លើយ បង្ហាញឆន្ទៈមិនព្រមសងប្រាក់មកឱ្យ ខ្ញុំបាទ/នាងខ្ញុំ វិញឡើយ។ ម៉្យាងទៀត ចុងចម្លើយ មិនដែលបង់ការប្រាក់ឱ្យ ខ្ញុំបាទ/នាងខ្ញុំ បានទៀងទាត់នោះទេ ពោលគឺ ក្នុងអំឡុងពេល........(.........)ខែចុងក្រោយនេះ ចុងចម្លើយ មិនបានបង់ការប្រាក់ឱ្យ ខ្ញុំបាទ/នាងខ្ញុំ សោះឡើយ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

.........................................................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សម្រេចតាមការទាមទាររបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............. .......កើត/រោច ខែ........... ឆ្នាំ......... ពុទ្ធសករាជ................

ធ្វើនៅ....................., ថ្ងៃទី....... ខែ............ ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

**សូមភ្ជាប់ជូននូវឯកសារ**

- កិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី..... ខែ.......... ឆ្នាំ.............. រវាងដើមចោទ និង ចុងចម្លើយ។
- ..........................................................................................។
- ..........................................................................................។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង( ទាមទារដី )

**<u>ដើមចោទ៖</u>** ឈ្មោះ ........................ ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ........... ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត..........................។

**<u>ចុងចម្លើយ៖</u>** ឈ្មោះ ........................ ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ........... ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត..........................។

## សូមគោរពចូលមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ក.<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖</u>

១. បង្គាប់ឱ្យចុងចម្លើយ ផ្ទេរកម្មសិទ្ធិ និង ប្រគល់អចលនវត្ថុ(ដី)ដែលមានទីតាំងស្ថិតនៅ.................
.................................................................................................. ឱ្យមក ខ្ញុំបាទ/នាងខ្ញុំ ។

២. បង្គាប់ឱ្យចុងចម្លើយ ចេញពីទីតាំងអចលនវត្ថុ(ដី)ដែលមានទីតាំងស្ថិតនៅ..............................
..................................................................................................................។

៣. បង្គាប់ឱ្យចុងចម្លើយសងប្រាក់ជម្ងឺចិត្តចំនួន.............(..................)រៀលឱ្យមក ខ្ញុំបាទ/នាងខ្ញុំ ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

### ខ.<u>អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារ</u>

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីអំឡុងឆ្នាំ.............. ឈ្មោះ.................. បានលក់អចលនវត្ថុ(ដី) ឱ្យមកខ្ញុំបាទ/នាងខ្ញុំ ក្នុងតម្លៃ.................(.....................)រៀល តាមរយៈកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី........ ខែ............ ឆ្នាំ............. រវាងខ្ញុំបាទ/នាងខ្ញុំ និង ចុងចម្លើយ។ ប៉ុន្តែនៅពេលដែលខ្ញុំបាទ/នាងខ្ញុំ និង ចុងចម្លើយ បានធ្វើការទូទាត់ប្រាក់ថ្លៃលក់-ទិញអចលនវត្ថុ(ដី)គ្រប់ចំនួនអស់ហើយ បែរជាចុងចម្លើយ មិនព្រមធ្វើការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ(ដី)ឱ្យមកខ្ញុំបាទ/នាងខ្ញុំ និង បានបន្តធ្វើការកាន់កាប់អចលនវត្ថុ(ដី)នោះ រហូតមកដល់ពេលបច្ចុប្បន្ននេះ។

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សម្រេចតាមការទាមទាររបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............. .......កើត/រោច ខែ........... ឆ្នាំ......... ពុទ្ធសករាជ.................

ធ្វើនៅ....................., ថ្ងៃទី...... ខែ............ ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

**សូមភ្ជាប់ជូននូវឯកសារ**

-កិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដី) ចុះថ្ងៃទី.... ខែ....... ឆ្នាំ.......... រវាងដើមចោទ និង ចុងចម្លើយ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ............... ចុះថ្ងៃទី..... ខែ.......... ឆ្នាំ.........។

-.......................................................................................................។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង(លែងលះ)

**<u>ដើមចោទ៖</u>** ឈ្មោះ ........................ ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... មានអាសយដ្ឋានបច្ចុប្បន្ន
នៅផ្ទះ........... ផ្លូវ.......... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ...............
រាជធានី/ខេត្ត...........................។

**<u>ចុងចម្លើយ៖</u>** ឈ្មោះ ........................ ភេទ.......... កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ៖ ........................ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... មានអាសយដ្ឋានបច្ចុប្បន្ន
នៅផ្ទះ........... ផ្លូវ.......... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ...............
រាជធានី/ខេត្ត...........................។

## សូមគោរពចូលមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ក.<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖</u>

**១.** លែងលះពីចុងចម្លើយឈ្មោះ........................................... ។
**២.** សុំគ្រប់គ្រងលើកូន.......(.......)នាក់ ឈ្មោះ............................, ឈ្មោះ............................,
ឈ្មោះ................................................. និង ............................................... ។
**៣.** សុំចែកទ្រព្យរួមតាមច្បាប់ ។
**៤.** បង្គាប់ឱ្យចុងចម្លើយ បង់អាហារកាតព្វកិច្ចដល់កូន.......(......)នាក់ ចំនួន.............................
(...........................)រៀល ក្នុង០១(មួយ)ខែ រហូតដល់កូនពេញវ័យនីតិភាព ក្លាយជានីតិជន។
**៥.** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

### ខ.<u>អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារ</u>

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីអំឡុងឆ្នាំ.................... ខ្ញុំបាទ/នាងខ្ញុំ និង ឈ្មោះ..................... ដែលជាចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ៖............. ចុះថ្ងៃទី...... ខែ.......... ឆ្នាំ..........។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ ខ្ញុំបាទ/នាងខ្ញុំ និង ចុងចម្លើយ យើងខ្ញុំមានកូនចំនួន.........(.........)នាក់ កូនទី១ឈ្មោះ..........................., កូនទី២ឈ្មោះ......................., កូនទី៣ឈ្មោះ........................... និង កូនទី៤ឈ្មោះ.......................... ហើយយើងខ្ញុំមាននូវ ទ្រព្យសម្បត្តិរួម(ដី, ផ្ទះ, រថយន្ត ឬ វត្ថុផ្សេង) ដូចជា................................................ និង ទ្រព្យសម្បត្តិដោយឡែក(ដី, ផ្ទះ, រថយន្ត ឬ វត្ថុផ្សេង) ដូចជា.................................. ម៉្យាងទៀត នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំពុំមានបំណុលរួមអ្វីឡើយ។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍បាន

.......(..........)ឆ្នាំ ការរស់នៅរបស់យើងខ្ញុំទាំងពីរ ចេះតែមានបញ្ហារវាងគ្នានឹងគ្នា តែងតែមានទំនាស់រកាំរកូសមិនចេះចប់មិនចេះហើយ ដោយមានការប្រើប្រាស់សំដីមិនសមរម្យដាក់គ្នា មិនចុះសម្រុងនឹងគ្នាជាញឹកញាប់ ដែលជាហេតុធ្វើឱ្យខ្ញុំបាទ/នាងខ្ញុំ អស់មនោសញ្ចេតនានឹងគ្នា ពុំអាចរស់នៅជាមួយចុងចម្លើយបន្តទៀតបានឡើយ។

..................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សម្រេចតាមការទាមទាររបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............. .......កើត/រោច ខែ........... ឆ្នាំ.......... ពុទ្ធសករាជ................

ធ្វើនៅ....................., ថ្ងៃទី...... ខែ............ ឆ្នាំ............

**ស្នាមមេដៃស្តាំ**

**សូមភ្ជាប់ជូននូវឯកសារ**

- សំបុត្រអាពាហ៍ពិពាហ៍លេខ៖.................... ចុះថ្ងៃទី...... ខែ........ ឆ្នាំ.........។
- ឯកសារសម្គាល់ទ្រព្យសម្បត្តិរួម(ដី, ផ្ទះ, រថយន្ត ឬ វត្ថុផ្សេងៗ).....................
 ............................................................................................។
- ឯកសារសម្គាល់ទ្រព្យសម្បត្តិដោយឡែក(ដី, ផ្ទះ, រថយន្ត ឬ វត្ថុផ្សេងៗ)........
 ............................................................................................។
- សំបុត្រកំណើត(កូន)លេខ៖............ ចុះថ្ងៃទី..... ខែ.......... ឆ្នាំ.........។
- ..........................................................................................។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

សាលក្រមលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
សំណុំរឿងរដ្ឋប្បវេណីលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## គាងនាមប្រជារាស្ត្រខ្មែរ

ការបរិច្ឆេទ នៃការបញ្ចប់ការទាញហេតុផលផ្ទាត់មាត់ ថ្ងៃទី ខែ ឆ្នាំ
កាលបរិច្ឆេទ នៃប្រកាសសាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ នៅ
សាលាដំបូង ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំទាមទារប្រាក់

**សមាសភាពជំនុំជម្រះ**

-លោក ជាចៅក្រមជំនុំជម្រះ

-លោក ជាក្រឡាបញ្ជីសវនាការ

**ភាគីដែលបង្ហាញខ្លួនជាអាទិ៍:**

-ដើមចោទឈ្មោះ តំណាងឲ្យ
អាសយដ្ឋានស្ថិតនៅ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

-អ្នកតំណាងដោយអាណត្តិឈ្មោះ អត្តលេខ និង ឈ្មោះ
អត្តលេខ ជាមេធាវីនៃ មានការិយាល័យនៅ
ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ ភេទ អាយុ ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ ភេទ
អាយុ ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ក្រុមទី ភូមិ ក្រុង ខេត្ត
។

-អ្នកតំណាងដោយអាណត្តិកញ្ញា អត្តលេខ ជាមេធាវីនៃ

## អង្គហេតុ និង ចំណុចខុសខាត

**សាលក្រមដែលទាមទារដោយដើមចោទ**

-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ( ) ដុល្លាអាមេរិច

-បង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់ ( ) ក្នុង ឆ្នាំ តាមការព្រមព្រៀងក្នុងកិច្ចសន្យាលើប្រាក់ដើម ( ) ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ថ្ងៃសងគ្រប់ចំនួន ( ) ដុល្លាអាមេរិក តាមការព្រមព្រៀង។

-បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ពិន័យតាមកិច្ចសន្យា ចំពោះការខកខានបង់ប្រាក់តាមការកំណត់ ( ) ក្នុង ឆ្នាំ ។

-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី ( ) រៀល លើពាក្យបណ្តឹង និងពន្ធផ្សេងៗ មក គ្រឹះស្ថាន វិញ ។

-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតចំនួន ( ) ដុល្លាអាមេរិក ។

-បង្គាប់ឲ្យចុងចម្លើយសងថ្លៃសេវាមេធាវីចំនួន ( ) ដុល្លាអាមេរិក ។

-សុំឲ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

## ការពន្យល់រឿងក្តីត្រួសៗ

-អង្គហេតុដែលជាមូលហេតុនៃការទាមទារ

នៅថ្ងៃទី ខែ ឆ្នាំ ឈ្មោះ និងឈ្មោះ បានខ្ចីចងការប្រាក់ពី គ្រឹះស្ថាន ចំនួន ( ) ដុល្លាអាមេរិក តាម រយៈកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ និងយល់ព្រមបង់ការប្រាក់ចំនួន ( ) ក្នុងមួយឆ្នាំ ។ ដើម្បីធានាបំណុលនេះ ចុងចម្លើយបានយកដី និងផ្ទះដែលមានលិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់លេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ក្រុង ខេត្ត មកដាក់បញ្ចាំនៅ គ្រឹះស្ថាន ។ តាមកិច្ចសន្យាខាងលើនេះ ឈ្មោះ និងឈ្មោះ បានសន្យាសងបំណុលឲ្យ គ្រឹះស្ថាន ក្នុងរយៈពេល ( ) ខែ ដោយបង់រំលោះក្នុងរយៈពេល ខែម្តង តាមតារាងបង់ប្រាក់គិតពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ថ្ងៃដែលសងប្រាក់គ្រប់ចំនួន ។ បន្ទាប់ពីបានទទួលប្រាក់កម្ចីពី គ្រឹះស្ថាន សរុបចំនួន ( ) ដុល្លាអាមេរិក រួចមកឈ្មោះ និងប្រពន្ធឈ្មោះ បានសងប្រាក់ដើមចំនួន ( ) ដុល្លាអាមេរិក តែប៉ុណ្ណោះ មកឲ្យ គ្រឹះស្ថាន ហើយក៏ឈប់បង់រហូតដល់ពេលបច្ចុប្បន្ននេះ ។ ទោះបីជាខាងគ្រឹះស្ថាន ព្យាយាមចេញលិខិត អញ្ជើញ ដាស់តឿនឲ្យសងប្រាក់ជាច្រើនដងក៏ដោយ ក៏ចុងចម្លើយទាំងពីរនាក់ប្តីប្រពន្ធពុំព្រមចូលមកដោះស្រាយ

ជាមួយ គ្រឹះស្ថាន ឡើយ ហេតុដូច្នេះទើបនៅថ្ងៃទី ខែ ឆ្នាំ

ដើមចោទក៏បានដាក់ពាក្យបណ្ដឹងមកតុលាការ ប្ដឹងសុំទាមទារប្រាក់ពីចុងចម្លើយតែម្ដង ។

-ភស្ដុតាង

-កិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី ខែ ឆ្នាំ រវាងអ្នកខ្ចីឈ្មោះ និងលោកស្រី និងអ្នកឲ្យខ្ចីឈ្មោះ ដែលមានមេធាវី ។

-កិច្ចសន្យាហ៊ីប៉ូតែកថ្ងៃទី ខែ ឆ្នាំ រវាងភាគីអ្នកបង្កើតហ៊ីប៉ូតែកឈ្មោះ និងភាគីម្ចាស់បំណុលហ៊ីប៉ូតែកឈ្មោះ ដែលមានមេធាវី មេភូមិ មេឃុំ ឈ្មោះ និងអភិបាលស្រុក ។

-លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ខែ ឆ្នាំ របស់អ្នកផ្ទេរលោក និងអ្នកស្រី ដែលមានសាក្សីទី១ ឈ្មោះ សាក្សីទី២ឈ្មោះ បានឃើញចៅសង្កាត់ ឈ្មោះ និងបានឃើញឯកភាពអភិបាលក្រុង ឈ្មោះ ។

-លិខិតរបស់នាយកប្រតិបត្តិនៃ គ្រឹះស្ថាន គោរពជូនលោកចៅសង្កាត់ សំណើសុំទប់ស្កាត់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-ពាក្យសុំទប់ស្កាត់ការលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិដីនិងផ្ទះ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-លិខិតជូនដំណឹងពីការបង់ប្រាក់របស់ គ្រឹះស្ថាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងមេធាវី ។

-លិខិតជូនដំណឹងពីការបង់ប្រាក់របស់ គ្រឹះស្ថាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងមេធាវី និងស្នាមមេដៃឈ្មោះ ត្រូវជា ។

-សៀវភៅគ្រួសារផ្ទះលេខ ក្រុមទី ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ។

-តារាងរូបមន្តគណនាការប្រាក់ និង ប្រាក់ពិន័យ ( លេខ ) សរុបប្រាក់ត្រូវបង់គិតត្រឹមថ្ងៃទី ខែ ឆ្នាំ ។

## អះអាងរបស់ភាគី

-មេធាវី តំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា៖

ខ្ញុំបានរក្សាការទាមទារដូចនៅក្នុងពាក្យបណ្ដឹងរបស់ឈ្មោះ និងសុំបញ្ជាក់បន្ថែមថា គ្រឹះស្ថាន គ្មានអញ្ជើញចុងចម្លើយឲ្យមកបង់ប្រាក់ជូន គ្រឹះស្ថាន តាមការកំណត់ក្នុងតារាងបង់ប្រាក់របស់ គ្រឹះស្ថាន វិញ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តទៅតាមការអញ្ជើញរបស់ គ្រឹះស្ថាន នៅឡើយ ។

ខ្ញុំសូមបញ្ជាក់ថា៖

១.ចុងចម្លើយបានខ្ចីប្រាក់ពី ត្រី:ស្ពាន សរុបចំនួន (ពីរម៉ឺនប្រាំពាន់) ដុល្លាអាមេរិច ដោយត្រូវបង់រំលោះរយ: ( ) ខែទៅតាមតារាងបង់ប្រាក់ ចុះថ្ងៃទី ខែ រហូតគ្រប់ចំនួន ប៉ុន្តែបានបង់ប្រាក់ដើមមកកូនក្តីខ្លួនចំនួន ( ) ដុល្លាអាមេរិក ប៉ុណ្ណោះ ហើយមិនបានបង់រហូតដល់សព្វថ្ងៃ ។ ប្រាក់ដើមដែលនៅសល់គឺ ( ) ដុល្លាអាមេរិក ។

២.ការប្រាក់ចំនួន ( ) ក្នុងមួយឆ្នាំ គឺទាមទារតាមការព្រមព្រៀងរបស់ភាគី ។ ការប្រាក់សុំគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតអនុវត្តកាតព្វកិច្ចចប់ ។

៣.ប្រាក់ពិន័យចំនួន ( ) គឺគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតបង់អស់ ។

៤-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតចំនួន ( ) ដុល្លាអាមេរិក ។

៥.ចុងចម្លើយត្រូវសងសោហ៊ុយសេវាមេធាវីរបស់ដើមចោទ ចំនួន ( ) ដុល្លាអាមេរិក ព្រោះដើមចោទចំណាយសេវាមេធាវីអស់ចំនួន ( ) ដុល្លាអាមេរិក។

៦.ការសុំឲ្យតុលាការប្រកាសសាលក្រមអនុវត្តជាបណ្តោះអាសន្នដោយហេតុថា កូនក្តីខ្លួនខ្ញុំបារម្ភថា ខ្លាចចុងចម្លើយប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីអូសបន្លាយពេលវេលាក្នុងការសងប្រាក់ ហើយធ្វើឲ្យខូចប្រយោជន៍កូនក្តីខ្ញុំធ្ងន់ធ្ងរ ជាងនេះទៅទៀត កូនក្តីខ្ញុំមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបញ្ជាក់បានថា ចុងចម្លើយពិតជាជំពាក់ប្រាក់តាមការទាមទាររបស់កូនខ្ញុំបាទមែន ។

-មេធាវី តំណាងដោយអាណត្តិឲ្យចុងចម្លើយបានថ្លែងការណ៍ថា៖

១.កូនក្តីខ្លួនពិតជាបានខ្ចីប្រាក់ពីត្រី:ស្ពាន ប្រាក់ចំនួន ( ) មែនហើយ តែបានសងខ្លះនៅសល់មិនទាន់សង ត្រី:ស្ពាន ប្រាក់ចំនួន ( ) ដុល្លាអាមេរិក ។

២.ចំពោះអត្រាការប្រាក់សូមឲ្យតុលាការអនុវត្តតាមផ្លូវច្បាប់ ក្នុងមួយឆ្នាំ មិនទទួលស្គាល់ ក្នុងមួយឆ្នាំដែលកូនក្តីខ្លួនព្រមព្រៀងជាមួយ ត្រី:ស្ពាន ។

៣.ប្រាក់ពិន័យសូមឲ្យតុលាការសម្រេចតាមការព្រមព្រៀង ដូចមានចែងក្នុងកិច្ចសន្យាខ្ចីចងការប្រាក់ និងអនុវត្តចាប់ពីថ្ងៃទី ខែ ឆ្នាំ ទៅ ។

៤.សូមច្រានចោលនៅការទាមទាររបស់មេធាវីដើមបណ្តឹង

-អត្រាការប្រាក់

-សំណងជំងឺចិត្ត និងថ្លៃសេវាមេធាវី

-ប្រាក់ពន្ធ និងប្រាក់ប្រម៉ាប់ក្តីសម្រាប់បណ្តឹង

## ចំណុចទទួល និងចំណុចគ្មានទទួល

-ចំណុចវិវាទ

១-អត្រាការប្រាក់ ។

២-សំណងចិត្តសងការខូចខាត ជាប្រាក់ចំនួន ( ) ដុល្លារអាមេរិក និង ថ្លៃសេវាមេធាវី ជាប្រាក់ចំនួន ( ) ដុល្លារអាមេរិក ។

៣-ប្រាក់ពន្ធ និង ប្រាក់ប្រដាប់ក្ដីលើពាក្យបណ្ដឹង ។

-ចំណុចគ្មានវិវាទ

១.ចុងចម្លើយបានខ្ចីប្រាក់ពី គ្រឹះស្ថាន សរុបចំនួន ( ) ដុល្លារអាមេរិច ដោយត្រូវបង់រំលោះរយៈ ( ) ខែទៅតាមតារាងបង់ប្រាក់ ចុះថ្ងៃទី ខែ រហូតគ្រប់ចំនួន ប៉ុន្តែបានបង់ប្រាក់ដើមមកកូនក្ដីខ្លួនចំនួន ( ) ដុល្លារអាមេរិក ប៉ុណ្ណោះ ហើយមិនបានបង់រហូតដល់សព្វថ្ងៃ ប្រាក់ដើមដែលនៅសល់ ( ) ដុល្លារអាមេរិក។

២.ប្រាក់ពិន័យចំនួន ( ) គឺគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតបង់អស់ ។

៣.សុំឲ្យតុលាការប្រកាសសាលក្រមអនុវត្តជាបណ្ដោះអាសន្ន ។

## សំអាងហេតុ

តាមលទ្ធផល នៃការសាកសួរសាមីខ្លួន និងពិនិត្យភស្តុតាង ក្នុងនីតិវិធីសាកសួរចប់សព្វគ្រប់៖

១-ពាក្យបណ្ដឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ដើមចោទឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចឲ្យតុលាការលើកយកធ្វើការទាញហេតុផលតាមបទបញ្ញត្តមាត្រា៩, មាត្រា ២៣ និងចេញសាលក្រមតាមបទបញ្ញត្តមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ដើមចោទឈ្មោះ តំណាងឲ្យ គ្រឹះស្ថាន បានទាមទារឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ( ) ដុល្លារអាមេរិក យោងភស្តុតាង កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ , កិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី ខែ ឆ្នាំ , លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់លេខ ចុះថ្ងៃទី ខែ ឆ្នាំ និងតារាងរូបមន្តគណនាការប្រាក់ និងប្រាក់ពិន័យ កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀង គ្មានវិការៈ ស្របតាមមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ចំណែកឯចុងចម្លើយក៏បានសារភាពថា ពិតជាបានខ្ចីលុយពី គ្រឹះស្ថាន ដូចការអះអាងរបស់ដើមចោទមែន ។ ការលើកឡើងនេះ ធ្វើឲ្យតុលាការជឿបាន ដោយហេតុថា ដើមចោទមានភស្តុតាងជាឯសារច្បាស់លាស់ អាចឲ្យតុលាការលើកយកពិចារណា និងសម្រេចបាន ។

៣-ការប្រគល់ ឬទទួលប្រាក់នេះ គឺជាការប្រគល់ក្រោមទម្រង់ជាកិច្ចសន្យាខ្ចីបរិភោគ ដោយអនុលោមតាមមាត្រា ៥៧៨ និងមាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី ហើយយើងពិនិត្យមើលឃើញថា ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមការវិភាគសងប្រាក់របស់ គ្រឹះស្ថាន នោះទេ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។

៤-ដើមចោទឈ្មោះ                    តំណាងឲ្យ គ្រឹះស្ថាន                                        បាន ទាមទារការប្រាក់                (                                  ) ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី      ខែ      ឆ្នាំ

ពីចុងចម្លើយឈ្មោះ           និងឈ្មោះ               យោងកិច្ចសន្យារបស់ភាគីពិតជាបានចែងអំពីការប្រាក់ចុះថ្ងៃទី     ខែ     ឆ្នាំ       ចំណែកឯចុងចម្លើយស្នើសុំ          (                    ) ក្នុងឆ្នាំ ។ ការទាមទាររបស់ចុងចម្លើយត្រឹមត្រូវតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លេខ ១២៦ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១១ ត្រង់ប្រការ១ និងប្រការ២ បានកំណត់ជាក់លាក់អំពីការកំណត់ការប្រាក់ថា:

- ប្រការ១ អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវកម្រិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ០១ (មួយ) ឆ្នាំ ។

- ប្រការ២ អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ ។

អនុលោមតាមប្រការខាងលើ ជាពិសេសត្រង់ប្រការ ២ តុលាការឃើញថា អត្រាការប្រាក់ដែលព្រមព្រៀងជាមុន គឺត្រូវកំណត់មិនឲ្យលើសពី ២៧% ក្នុងមួយឆ្នាំឡើយ (១៨% x ១,៥ = ២៧%) ឬស្មើនឹង ២,២៥ ក្នុងមួយខែ ។ ដោយពិនិត្យទៅលើការទាមទារអត្រារបស់ចុងចម្លើយគឺមានចំនួន ១,៥% ក្នុងមួយខែ ស្មើនឹង ១៨% ក្នុងមួយឆ្នាំ ត្រឹមត្រូវនឹងគោលការណ៍ខាងលើ ដូច្នេះតុលាការគប្បីសម្រេចអំពើអត្រាការប្រាក់តាមស្នើសុំរបស់ចុងចម្លើយ ។

៥-គ្រឹះស្ថាន                                                    ដោយមានឈ្មោះ                   ជាអ្នកតំណាង បានទាមទារថ្លៃសេវាមេធាវី ពីចុងចម្លើយឈ្មោះ            និងឈ្មោះ                  សងការខូចខាតចំនួន      (            ) ដុល្លាអាមេរិក និងសងថ្លៃសេវាធាវីចំនួន          (         ) ដុល្លាអាមេរិក ប៉ុន្តែដោយហេតុថា ដើមចោទមិនបានបង្ហាញភស្តុតាងទាក់ទង ទៅនឹងចំណាយលើសេវាមេធាវី មកតុលាការនោះទេ ដូច្នេះតុលាការនឹងធ្វើការសម្រេចតាមតថភាពជាក់ស្តែង ដោយអនុលោមតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ។

៦-គ្រឹះស្ថាន                                                    តំណាងដោយឈ្មោះ                   សុំតុលាការអនុវត្តន៍សាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម តុលាការយល់ឃើញផងដែរថា មានភាពចាំបាច់នៅក្នុងការអនុវត្តជាបណ្តោះអាសន្ន យោងតាមមាត្រា ១៩៦ នៃនីតិវិធីក្រមរដ្ឋប្បវេណី ដូច្នេះតុលាការគប្បីសម្រេចអនុវត្តន៍បណ្តោះអាសន្នសាលក្រមនេះជាបណ្តោះអាសន្ន ។

៧-ចំពោះប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន " ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

I. ទទួលស្គាល់បណ្តឹងរបស់ដើមចោទទុកជាបានការស្របតាមច្បាប់ ។

II. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ សងប្រាក់ដើមចំនួន ( ) ដុល្លាអាមេរិក និងការប្រាក់ ១៨% (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ពេលសងប្រាក់អស់ ទៅ គ្រឹះស្ថាន ។

III. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ បង់ប្រាក់ពិន័យ ( ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលត្រូវបង់ឲ្យដើមចោទ គ្រឹះស្ថាន គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតអនុវត្តកាតព្វកិច្ចចប់ ។

IV. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ សងសោហ៊ុយសេវាមេធាវី ចំនួន ( ) ដុល្លាអាមេរិក ឲ្យគ្រឹះស្ថាន ។

V. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ។

VI. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រមជំនុំជម្រះ**